ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2015, 13:15
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៧នាទី**

**សវនាការលើកទី៣០៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជើ ហ្វីលីព *(Mr. Roger Phillip)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ត្រាវីស ហ្វារ *(Mr.* Mr. Travis FARR)

លោក ចូសេហ្វ អេនឌ្រូ ប៊យលី *(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr. Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ួច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក ឡេង ជុនធី | ខ្មែរ |
| លោក កាន ថុល (2-TCW-881 ) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កាន ថុល** (2-TCW-881)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២៧
សួរដោយលោក សេង លាង ផ្ដើមពី ....................ទំព័រ ២៩
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្ដើមពី ....................ទំព័រ ៤០
សួរដោយលោក ឡោ ជុនធី ផ្ដើមពី....................ទំព័រ ៥៤
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ....................ទំព័រ ៥៧

# កិច្ចដំណើរការនីតិវិធី

[០៩:០៧:២៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគសវនាការនៅថ្ងៃនេះ គឺអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលទាក់ទងនឹងអង្គហេតុទំនប់ត្រពាំងថ្មជាបន្តទៀត។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយតាមព័ត៌មានពីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានជូនដំណឹងមកថា សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ ដែលមានរហស្សនាម 2-TCW-845 និងសាក្សីបម្រុងមួយទៀតដែលមានរហស្សនាម 2-TCW-876 មិនអាចមកផ្តល់សក្ខីកម្មបានទេ។ ប៉ុន្តែមានសាក្សីមួយរូបទៀតដែលមានរហស្សនាម 2-TCW-881 នឹងមានវត្តមាននៅ អ.វ.ត.ក នៅពេលព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៨:៥២]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខ-ភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥។

បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះ ឆ្អឹងខ្នង មិនអាចអង្គុយបានយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៩:៣៦]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

តាមគម្រោង អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-845 ទាក់ទងនឹងអង្គហេតុទំនប់ត្រពាំងថ្ម ប៉ុន្តែដោយសារតែសាក្សីរូបនេះមានបញ្ហាសុខភាពដែលមិនអាចផ្តល់សក្ខីកម្មបាននៅថ្ងៃនេះ ហើយសាក្សីបម្រុងដែលអង្គជំនុំជម្រះគ្រោងនឹងស្តាប់សក្ខីកម្មនៅថ្ងៃនេះដែលមានរហស្សនាម 2-TCW-876 មានធុរៈចាំបាច់មិនអាចមកផ្តល់សក្ខីកម្មតាមកាលបរិច្ឆេទដែលបានកំណត់ដែរនោះ ហេតុដូច្នេះអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-881 នៅរសៀលនេះចាប់ផ្តើមនៅម៉ោងមួយសាមសិបនាទី។

អង្គជំនុំជម្រះកត់សម្គាល់ទៅលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំធ្វើសេចក្តីសន្និដ្ឋាន ដោយផ្អែកលើព័ត៌មានដែលមាននៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០៣ និង០៤។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ព័ត៌មានថ្មីនេះ អាចនាំឲ្យប៉ះពាល់ដល់ការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវថ្លែងទុក្ខសោកវេទនា និងព្យសនកម្ម ដែល

ទទួលរងទាក់ទិននឹងការដ្ឋានការងារ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាដល់ភាគីនីមួយៗ ចំនួន ១០នាទី ដើម្បីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទៅលើបញ្ហានេះ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះធ្វើការកត់សម្គាល់ដូចខាងក្រោម។

ទី១ ការអនុញ្ញាតឲ្យជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០៣ និង០៤ ដើម្បីថ្លែងទុក្ខសោកវេទនា និង ព្យសនកម្ម ដែលទទួលរងគឺមានកំហិត ដោយហេតុថា មានតែដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ប៉ុណ្ណោះ ដែលអាចត្រូវបានជ្រើសរើស។ អ្នកស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០៣ និង ០៤ ដែលមិនមែនជាភាគីនៅក្នុងសំណុំរឿង០០២ មិនអាចត្រូវបានអនុញ្ញាតឲ្យជ្រើសរើសដើម្បីមកថ្លែងទុក្ខសោកវេទនា និងព្យសនកម្មទេ។ ទី២ អង្គជំនុំជម្រះបានបញ្ជាក់ប្រាប់ភាគីរួចហើយថា ខ្លួននឹងពិចារណាទៅលើសំណើដែលមានហេតុផលសមស្រប ដើម្បីកោះហៅសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមកវិញ ក្នុងករណីដែលមានអង្គហេតុថ្មី នៅក្នុងឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង០៣ និង ០៤។ ហេតុនេះការរួមបញ្ចូលទាំង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០៣ និង ០៤ ផងដែរ។

ដោយពិចារណាពីស្ថានភាពទាំងនេះ អង្គជំនុំជម្រះសូមអញ្ជើញភាគីធ្វើសារណារផ្ទាល់មាត់ពាក់ព័ន្ធនឹងសំណើសុំក្នុងការដាក់បង្ហាញឯកសារពីក្នុងសំណុំរឿងលេខ ០៣ និង ០៤ ទៅក្នុងសំណុំរឿងនេះ។ ឥឡូវនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាដល់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសារណាផ្ទាល់មាត់ពីសំណើសុំរបស់ខ្លួន។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំមានសំណើសុំខ្លីមួយផ្អែកតាមអ៊ីម៉ែលដែលបានផ្ញើជូនអង្គជំនុំជម្រះ និងភាគីកាលពីថ្ងៃសុក្រ គឺនៅពេល ចុងពេលព្រឹក។ ជាបឋមខ្ញុំចង់និយាយខ្លះៗពាក់ព័ន្ធទៅនឹងមូលហេតុដែលយើងបានផ្ញើអ៊ីម៉ែល ហើយនិងមូលហេតុដែលយើងមិនបានធ្វើសំណើជាលាយលក្ខណ៍អក្សរដែលយើងអាចបកប្រែជាពីរភាសាបាននោះ គឺដោយសារតែវាមានភាពប្រញាប់ពេក ហេតុនេះហើយទើបបានជាយើងសុំឲ្យអង្គជំនុំជម្រះធ្វើកិច្ចពិភាក្សានៅថ្ងៃនេះ ដើម្បីឲ្យយើងអាចពិភាក្សាតទល់គ្នាអំពីបញ្ហាទាំងអស់នេះ។

យើងទទួលបានព័ត៌មានសំខាន់ៗពីការិយាល័យសហព្រះរាជអាជ្ញា កាលពីថ្ងៃព្រហស្បតិ៍រសៀលព័ត៌មានទាំងអស់នេះមានផលប៉ះពាល់ផ្ទាល់ទៅលើបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីដែលយើងបានរៀបចំរួច

មកហើយសម្រាប់ផ្ញើជូនជាផ្លូវការទៅកាន់អង្គជំនុំជម្រះ និងភាគីសម្រាប់នៅថ្ងៃសុក្រ។ ចំពោះយើង គឺខាងផ្នែកសម្ភារៈយើងមិនអាចសរសេរសំណើ ហើយនិងធ្វើការបកប្រែនៅថ្ងៃសុក្រទាន់ទេ។ ហេតុអ៊ីចឹងហើយបានជាយើងផ្ញើអ៊ីម៉ែលជូនអង្គជំនុំជម្រះ ដើម្បីស្នើសុំឱ្យមានការពិភាក្សាជាសាធារណៈទៅលើបញ្ហានេះ ហើយជាលក្ខណៈបន្ទាប់បន្សំថែមទៀតនេះ គឺមានការអនុញ្ញាតឱ្យយើងបង្ហាញឯកសារដែលបាន -- ដែលយើងនឹងផ្ញើជូនអង្គជំនុំជម្រះ។ ដោយសារតែយើងមិនទទួលបានពេលវេលា -- ចម្លើយ -- និងពេលវេលាគ្រប់គ្រាន់ យើងបានសម្រេចដាក់បញ្ជីដើមបណ្ដឹងរដ្ឋប្បវេណីរបស់យើងកាលពីថ្ងៃសុក្រមុនម៉ោងបី ដែលជាម៉ោងតម្រូវសម្រាប់ឱ្យមានការចុះបញ្ជីឯកសារដោយក្រឡាបញ្ជី។

យើងសូមបញ្ជាក់ថា នៅក្នុងឯកសារនុំង យើងស្នើសុំលទ្ធភាពក្នុងការពិនិត្យមើលឡើងវិញ នៅបញ្ជីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានដាក់ភ្ជាប់ទៅនឹងឯកសារនោះ ដោយផ្អែកទៅលើការសិក្សា ទៅលើពាក្យសុំតាំងខ្លួនចាំដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានលើកឡើងដោយការិយាល័យសហព្រះរាជអាជ្ញានៅក្នុងសំណើរបស់ពួកគាត់នៅថ្ងៃព្រហស្បតិ៍។ អ្វីដែលយើងស្នើសុំ គឺសាមញ្ញបំផុត គឺយើងស្នើសុំលទ្ធភាពក្នុងការពិនិត្យមើលឡើងវិញនូវបញ្ជីដែលបានផ្ញើជូនកាលពីថ្ងៃសុក្រ ជូនអង្គជំនុំជម្រះ ហើយយើងសុំពេលវេលាបន្ថែមពីរសប្ដាហ៍ ហើយខ្ញុំនឹងពន្យល់ពីមូលហេតុថា តើហេតុអ្វីបានជាយើងសុំពេលវេលាពីរសប្ដាហ៍។

យើងទទួលបានព័ត៌មានពីការិយាល័យសហព្រះរាជអាជ្ញា ថាប្រហែលជា២០០ ទៅ២៥០ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធទៅនឹងអាងត្រពាំងថ្ម និងត្រូវដាក់ជូនទៅឱ្យភាគីទាំងអស់ប្រើប្រាស់នៅក្នុងសប្ដាហ៍នេះ។ ក៏ប៉ុន្តែយើងតាមផ្នែកសម្ភារៈ យើងមិនអាចដឹងថាតើឯកសារអ្វីខ្លះនៅក្នុងចំណោមឯកសារទាំង២៥០នេះ ដែលពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២។

ឥឡូវនេះ យើងមិនមានលទ្ធភាពអ្វីដើម្បីដឹង ថាតើនៅក្នុងចំណោមឯកសារទាំង២៥០ ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងផ្ដល់ជូនភាគីនៅថ្ងៃនេះនោះ តើមានឯកសារណាខ្លះដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីបីរូប ដែលយើងបានជ្រើសរើសសម្រាប់អាងត្រពាំងថ្ម ដើម្បីមកផ្ដល់សក្ខីកម្មនៅពេលដែលធ្វើសវនាការអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម។ ដូច្នេះ យើងត្រូវការពេលវេលាអប្បបរមាដើម្បីឱ្យដឹងច្បាស់អំពីឯកសារទាំងអស់នោះ ចាប់តាំងពីពេលដែលយើងអាចចូលមើលបានដើម្បីពិនិត្យផ្ទៀងផ្ទាត់ ថាតើឯកសារដែលបានផ្សព្វផ្សាយនោះ វាពាក់ព័ន្ធនឹងដើម

បណ្ដឹងរដ្ឋប្បវេណីទាំងបីឬក៏អត់? ហើយជាលក្ខណៈទូទៅ ថាតើឯកសារណាខ្លះត្រូវបានដាក់បង្ហាញ ដែលបានប៉ះពាល់ដោយផ្ទាល់ទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២ សម្រាប់វគ្គត្រពាំងថ្ម។

ដូច្នេះ យើងបានដាក់បញ្ជីរបស់យើងរួចមកហើយ ក៏ប៉ុន្តែយើងចង់ឲ្យអង្គជំនុំជម្រះផ្ដល់លទ្ធភាពឲ្យយើងកែប្រែក្នុងករណីជាយថាហេតុនូវបញ្ជីនេះឡើងវិញ ចាប់ពីថ្ងៃនេះរហូតដល់ពីរសប្ដាហ៍ខាងមុខ។ ផលវិបាកនៃសំណើនេះ គឺថាសវនាការផលប៉ះពាល់ទៅលើឧក្រិដ្ឋកម្មត្រូវលើកពេល។ ដូច្នេះអង្គជំនុំជម្រះគួរតែសម្រេចថា តើអ្វីសមស្របយ៉ាងម៉េច ដើម្បីលើកពេលវេលាពាក់ព័ន្ធទៅនឹងសវនាការពីរថ្ងៃដែលធ្វើទៅលើផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជំរំការងារ ដូចជា ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង និងត្រពាំងថ្ម។ ដូច្នេះ អង្គជំនុំជម្រះអាចលើកពេលថ្ងៃនេះ ឬមួយក៏អង្គជំនុំជម្រះអាចសម្រេចស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធទៅនឹងទំនប់ ១មករា ហើយនិងកំពង់ឆ្នាំង ហើយលើកពេលការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកផ្ដល់សក្ខីកម្មអំពីព្យសនកម្ម ដែលបានទទួលរងពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅត្រពាំងថ្ម។

យើងក៏សូមជម្រាបជូនអង្គជំនុំជម្រះផងដែរ ថាការផ្ដល់ជូនដាក់ពាក្យសុំតាំងខ្លួនជាច្រើននេះ គឺនឹងមានផលប៉ះពាល់ទៅលើការជ្រើសរើសដែលយើងបានធ្វើរួចមក ដែលនឹងធ្វើពាក់ព័ន្ធទៅនឹងឯកសារដែលនឹងបង្ហាញជូននៅក្នុងសវនាការនាពេលខាងមុខ ពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារគន្លឹះ។ ហេតុអ្វី? ពីព្រោះថាអង្គជំនុំជម្រះ ហើយនិងភាគីបានដឹងច្បាស់រួចមកហើយថា ចាប់តាំងពីដើមសវនាការ០០២មក យើងបានជ្រើសរើសធ្វើការបង្ហាញឯកសារដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសវនាការជាសាធារណៈ ហើយយើងត្រូវពិនិត្យផ្ទៀងផ្ទាត់ ថាតើនៅក្នុងឯកសារទាំង២៥០ ហើយនិងឯកសារមួយចំនួនទៀតដែលនឹងផ្ដល់ជូននោះ វាមិនមានឯកសារពាក់ព័ន្ធនឹងផ្ទាល់ទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២។

[០៩:១៥:០០]

ជាចុងក្រោយ សំណើរបស់យើង ហើយយើងផ្ដល់ជូនទៅអង្គជំនុំជម្រះ ហើយជាពិសេសយើងសំដៅទៅលើការិយាល័យសហព្រះរាជអាជ្ញាផងដែរ គឺយើងសុំឲ្យមានការបំភ្លឺឲ្យបានច្បាស់។ យើងគិតថានេះ គឺជាផលប្រយោជន៍របស់ភាគីទាំងអស់ក្នុងការទទួលបានព័ត៌មានច្បាស់លាស់អំពីរបៀបដែលការិយាល័យសហព្រះរាជអាជ្ញាចង់ធ្វើជូនទៅដល់ភាគីនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅសេសសល់ នៃសំណុំរឿង០០៣ និង ០០៤។ បញ្ហាដែលយើងកំពុងតែជួបប្រទះនោះគឺថា ការិយា-

ល័យសហព្រះរាជអាជ្ញាគាត់ចង់ផ្តល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០៣, ០០៤ ដែរឬទេ? សំណួរទី២ វាពាក់ព័ន្ធនឹងផ្នែកណាខ្លះ? ហើយសំណួរទី៣ ថាតើយើងនឹងទទួលបានព័ត៌មានអំពីការដាក់បង្ហាញពាក្យសុំតាំងខ្លួនហ្នឹងក្នុងកម្រិតណា ដើម្បីឱ្យយើងអាចគិតទុកជាមុននូវការងាររបស់យើង។ យើងជាការិយាល័យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី យើងត្រូវធ្វើការជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់។ ដូច្នេះ នេះជាសំណើរបស់យើងគឺយើងសុំពេលវេលាពីរសប្តាហ៍ដើម្បីដាក់នូវឧបសម្ព័ន្ធដែលត្រូវបានធ្វើបច្ចុប្បន្នភាពនៃដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងព្យសនកម្ម ហើយយើងស្នើសុំឱ្យអង្គជំនុំជម្រះគិតទៅលើការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលអង្គជំនុំជម្រះផ្តល់ជូនពេលវេលាដល់យើង ក្នុងការកំណត់អត្តសញ្ញាណនៃឯកសារគន្លឹះពាក់ព័ន្ធទៅនឹងជំរំការងារ ការដ្ឋានការងារ ហើយយើងសុំឱ្យសហព្រះរាជអាជ្ញាផ្តល់ព័ត៌មានចំបាច់ដល់យើង ដើម្បីឱ្យយើងអាចរៀបចំផែនការការងាររបស់យើងដើម្បីឱ្យមានប្រសិទ្ធភាពបំផុត។ សូមអរគុណលោកប្រធាន។

[០៩:២២:៣៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ជាក់ថែមបន្តិចពាក់ព័ន្ធទៅនឹងអ្វីដែលលោកប្រធានស្តីទីបានធ្វើការកត់សម្គាល់ពីចំណុចអម្បាញ់មិញ។ ពាក់ព័ន្ធទៅនឹងឯកសារថ្មីនេះ ខ្ញុំបាទសូមជម្រាបជូនថា មេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនមានបំណងនៅក្នុងការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីដែលស្ថិតនៅក្នុងករណី០៣, ០៤ សុទ្ធសាធមកធ្វើជា -- មកផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងព្យសនកម្ម ឬក៏ការឈឺចាប់នោះទេ។ អ្វីដែលមេធាវីនាំមុខចង់ពិនិត្យមើល គឺចង់ដឹងថាតើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ឯកសារផ្សេងទៀតដែលបង្ហាញ ឬក៏ដាក់ឱ្យប្រើប្រាស់បានដោយការិយាល័យសហព្រះរាជអាជ្ញានេះ មានព័ត៌មានដើមបណ្តឹងរដ្ឋប្បវេណីដែលនៅក្នុង ០៣ ផង ឬក៏ ០៤ៗ ហើយក៏ជាដើមបណ្តឹងរដ្ឋប្បវេណី អ្នកទាំងនោះក៏ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី០០២ ផងដែរ ដែលអាចព័ត៌មានទាំងអស់នោះមានផលប៉ះពាល់ទៅលើការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០២ នេះមកផ្តល់សក្ខីកម្មផ្នែកពាក់ព័ន្ធទៅនឹងព្យសនកម្ម ហើយក៏អាចមាន

ឯកសារផ្សេងៗទៀត ដែលអាចមានផលប៉ះពាល់មកដល់ការជ្រើសរើសនេះដែរ។ ដូច្នេះ វាជាការចាំបាច់ណាស់ដែលពួកយើងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានពិនិត្យឯកសារទាំងអស់នោះដោយហ្មត់ចត់ មុននឹងធ្វើការជ្រើសរើសពួកគាត់មកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងព្យសនកម្មនេះ។

សូមអរគុណលោកប្រធាន និងលោក លោកស្រីចៅក្រម សូមអរគុណ។

[០៩:២៤:៣០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

សូមអញ្ជើញ -- ជាបន្តទៀត សូមជូនវេទិកាទៅលោកសហព្រះរាជអាជ្ញា។

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ សហព្រះរាជអាជ្ញាមិនជំទាស់ក្នុងការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបញ្ជី ការថ្លែងពីផលប៉ះពាល់ទៅដល់ជនរងគ្រោះទេ លើកលែងតែមានការលើកលែងមួយ គឺលើកលែងតែបញ្ជីនោះត្រូវបានដាក់ជូនទៅភាគីប៉ុន្មានថ្ងៃជាមុន មុនទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី មុនពួកគាត់មកដល់តុលាការ។ ប្រសិនបើមានការកែប្រែអ្វីមួយ--

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា សូមកាត់លោកបន្តិច ពីព្រោះខាង -- អ្នកបកប្រែសុំផ្អាកមួយ។

[០៩:២៧:៤០]

*(មានបញ្ហាបច្ចេកទេស)*

[០៩:៣១:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្ត!

**លោក វីល្លៀម ស្មីត៖**

និយាយដោយសង្ខេប សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេក្នុងការកែតម្រូវ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលទាក់ទងទៅនឹងអាងត្រពាំងថ្មនោះ។ ប៉ុន្តែយើងនឹងបញ្ជាក់ទាក់ទងទៅនឹង ឆ្លើយតបទៅនឹងការស្នើសុំពន្យារ

ពេលនោះ គឺថាពាក្យសុំទាំងអស់នេះ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០៣, ០០៤ នោះ គឺលើកលែងតែករណីដែលគាត់មានពាក្យសុំនៅក្នុងរឿងក្តី០០២ ដែលអាចនឹងត្រូវកោះអញ្ជើញមកផ្តល់សក្ខីកម្ម ឬក៏ថ្លែងទុក្ខ។ ហើយយើងនឹងផ្តល់ឱកាសផងដែរឲ្យពួកគាត់មើលបញ្ជីរបស់គាត់ ដើម្បីយើងឲ្យដឹងថាតើដើមបណ្តឹងរដ្ឋប្បវេណីណាដែលស្ថិតនៅក្នុងរឿងក្តី០០៣ និង ០០៤ ហើយការធ្វើបែបនោះ គឺថាយើងមិនប្រើពេលវែងទេ យើងនឹងមើលបញ្ជីឈ្មោះ ហើយនិងមានឯកសារអ្វីដែលពាក់ព័ន្ធតែប៉ុណ្ណោះ។ ទាក់ទងទៅនឹងការស្នើសុំឲ្យមានពន្យារពេលសវនាការលើឯកសារគន្លឹះមួយចំនួន ហ្នឹងគឺថាពាក្យសុំនោះ គឺថាទាក់ទងទៅនឹងរឿងក្តីត្រពាំងថ្ម អង្គហេតុត្រពាំងថ្មនោះទេ។ ហើយជាសំណើដែលថាសមហេតុផលគឺថា យើងអាចនឹងប្រើពេលមួយថ្ងៃ ពីរថ្ងៃ ពិនិត្យមើលឯកសារទាំងអស់នោះ ដើម្បីនឹងដាក់បង្ហាញដើម្បីឲ្យដឹងថាតើត្រូវប្រើឯកសារណានៅក្នុងកិច្ចដំណើរការនីតិវិធី។

លោកចៅក្រម ហើយមុននឹងសម្រេចលើបញ្ហានេះ យើងខ្ញុំស្នើថា សូមឲ្យអង្គជំនុំជម្រះរក្សាការវិភាគទៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយនិងការដ្ឋានទំនប់ ១មករា ទាក់ទងទៅនឹងសវនាការលើផលប៉ះពាល់ និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងអាងត្រពាំងថ្មនោះផងដែរ។ ប៉ុន្តែទាក់ទងទៅនឹងឯកសារមួយចំនួនយើងមិនមានការជំទាស់នៅក្នុងការពន្យារពេលឯកសារមួយចំនួនដែលភាគីស្នើសុំទៅសវនាការនៅថ្ងៃពេលក្រោយ។ ហើយបើសិនជាសហមេធាវីនាំមុខគាត់មិនយល់ស្របទេ ហើយទៅថ្ងៃក្រោយ។ ហើយសហព្រះរាជអាជ្ញាក៏បានបញ្ជាក់ពីដើមមកដើមដែលថាប្រការសំខាន់ គឺសវនាការស្តាប់ ព្យសនកម្មរបស់ជនរងគ្រោះគឺទាក់ទងទៅនឹងផ្នែកនៃសវនាការនីមួយៗដោយមានភាពទាក់ទងគ្នា។

[០៩:៣៤:២៦]

ហើយមូលហេតុសំខាន់គឺថា ភាគីនានា ដូចចៅក្រម ហើយនិងភាគីទាំងអស់ហ្នឹងអាចដឹងថាតើលំដាប់លំដោយនោះយ៉ាងដូចម្តេច វាទាក់ទងគ្នាដើម្បីឲ្យគេយល់ ហើយនិងភស្តុតាងទាំងស្រុងទាក់ទងទៅនឹងផ្នែកនីមួយៗនៃសវនាការនោះ។ ដូច្នេះ យើងនឹងចង់ឲ្យបានគឺថា សវនាការលើផលប៉ះពាល់ព្យសនកម្មហ្នឹងគឺត្រូវនៅបន្ទាប់វគ្គនីមួយៗនៃសវនាការ។ ប៉ុន្តែបើយើងទុកទៅចុងក្រោយទាំងអស់នោះក៏វាអាចមានការលំបាក។ ប៉ុន្តែបើយើងរក្សានោះ គឺថាតាមសំណើនេះ គឺថាយើងសូមឲ្យតុលាការមិនកែប្រែកាលវិភាគសម្រាប់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងទេ ហើយទំនប់ ១មករាក៏ដូចនោះដែរ។ ហើយនិងសវនាការស្តាប់ព្យសនកម្មសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីនៅត្រពាំងថ្មក៏យើងមិនជំទាស់

នោះដែរ ជាពិសេសទាក់ទងទៅនឹងត្រពាំងថ្ម អាងត្រពាំងថ្ម អាចនឹងទុកមួយសប្តាហ៍ ឬក៏ពីរសប្តាហ៍ ហើយយើងក៏មិនមានការជំទាស់ទៅនឹងការកែប្រែបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងទុក្ខ ឬក៏ផលប៉ះពាល់នៅអាងត្រពាំងថ្មនោះដែរ ប្រសិនបើមានការចាំបាច់បែបនោះ។

លោក លោកស្រី លោកចៅក្រម ខ្ញុំកត់សម្គាល់ថា យើងពិភាក្សាព្រឹកនេះឲ្យបានលម្អិតតាមដែលអាចទៅបាន គឺថាចុងក្រោយ គឺថ្ងៃទី២៧ ខែកក្កដា នោះ គឺថាបញ្ជីនោះនិយាយអំពីការ -- កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញឯកសារ ហើយនិងសារៈសំខាន់នៃការបង្ហាញភស្តុតាងដែលអាចដោះបន្ទុកនោះផងដែរ ហើយនិងផ្តល់ភស្តុតាងដែលអាចនឹងជាស្ថានសម្រាល ហើយនិងបង្ហាញអំពីការគ្មានទោសនៃជនជាប់ចោទ ហើយអាចនឹងជាបញ្ហាក់ពីការជឿជាក់បាននៅលើកាតព្វកិច្ច ហើយនេះជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា។

[០៩:៣៦:៥៥]

អង្គជំនុំជម្រះក៏បានជម្រាបយើងដែរ ហើយយើងសូមជម្រាបថា សហព្រះរាជអាជ្ញា គឺថាចាត់ទុកថាការដាក់បង្ហាញឯកសារនេះជាអាទិភាពដ៏ចម្បងរបស់ខ្លួន។ រឿងក្តីនេះជារឿងក្តីធំ ហើយមិនដែលបានពាក់ -- ហើយគឺពាក់ព័ន្ធទៅនឹងឯកសាររាប់ពាន់ទំព័រឯណោះ ហើយក្នុងន័យនេះ គឺថាមានតែសហព្រះរាជអាជ្ញាទេដែលអាចនឹងជម្រាបដាក់បង្ហាញ ហើយភាគីដូចជាសហមេធាវីការពារក្តីក៏មានកាតព្វ-កិច្ចក្នុងការពិនិត្យមើលដែរ។ នៅពេលដែលភាគីខ្លួនមានការយល់ហើយវាស្មុគ មានការលំបាក ហើយស្មុគស្មាញពេកនៅក្នុងដំណើរការ ប៉ុន្តែជាអកុសល គឺថាវាជាការលំបាកបែបនេះឯង ពីព្រោះជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយនិងមានការបំពារបំពានធ្ងន់ធ្ងរបែបនេះ ទៅលើប្រជាជនធំធេងទូទាំងប្រទេស ហើយមិនមែនជារឿងក្តីសាមញ្ញទេ។ ដូច្នេះ នេះហើយជាលក្ខណៈនៃការលំបាក ហើយសាលាក្តីផ្សេងៗទៀតដូចគ្នាដែរ គឺថាការដាក់បង្ហាញឯកសារនេះ គឺជាបញ្ហាសំខាន់ដើម្បីធានាថា មេធាវីការពារក្តីមានលទ្ធភាពនឹងមើលឯកសារ ហើយនិងមានឱកាសក្នុងការបង្ហាញឯកសារទាំងអស់នោះបើសិនជាខ្លួនចង់បង្ហាញ ហើយនិងជំទាស់នោះផងដែរ។

យើងយល់ស្របជាមួយវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ជាពិសេសគោលការណ៍ដែលអង្គជំនុំជម្រះបានដាក់ចេញកាលពីដើមដំបូងនៃសវនាការនេះ។ ប្រសិនបើឯកសារថ្មី ហើយពាក្យសុំតាំងខ្លួនថ្មី ឬក៏ពាក្យសុំថ្មី ដែលនាំភស្តុតាងថ្មីសម្រាប់ជាប្រយោជន៍របស់មេធាវីការពារក្តី របស់សហព្រះរាជអាជ្ញាដែលមិនមានពីមុនមក គឺអង្គជំនុំជម្រះបានពិនិត្យមើលឱកាសក្នុងការនឹងកោះហៅសាក្សី ឬក៏ភាគី

នោះ ដើម្បីឲ្យភាគីអាចដាក់បង្ហាញរឿងក្ដីរបស់ខ្លួនឲ្យបានសមស្រប ហើយយើងក៏យល់ស្របជាមួយជំហររបស់អង្គជំនុំជម្រះដែលថាៗ មេធាវីការពារក្ដី សហព្រះរាជអាជ្ញា ហើយនិងសហមេធាវីនាំមុខអាចនឹងត្រូវអនុញ្ញាតឲ្យកោះសាក្សីនោះមកវិញ បើសិនជាមានភស្តុតាងថ្មី ប្រសិនបើសក្ខីកម្មដែលបានផ្ដល់មក គឺថាវាជាភស្តុតាងថ្មី ហើយភាគីមិនមានឱកាសក្នុងការជំទាស់នៅពេលនោះទេ ដោយសារការបង្ហាញឯកសារនោះ ជាភស្តុតាងថ្មី។

[០៩:៣៩:៣៧]

នៅក្នុងករណីនេះ ខ្ញុំបានអានប្រតិចារឹកនៅថ្ងៃទី២៧ ថ្ងៃចន្ទ ខែកក្កដា ដែលលើកឡើងដោយសហព្រះរាជអាជ្ញា មេធាវីការពារក្ដីនោះផងដែរ គឺថាចំណុចមួយដែលខ្ញុំចង់និយាយបន្ថែមទៀតនោះ គឺថា លោកចៅក្រមបានជ្រាបហើយថា មានការស៊ើបអង្កេតពីរកំពុងអនុវត្តទៅ គឺរឿងក្ដី ០០៣, ០០៤ ហើយយើងអាចជាការចង្អុលបង្ហាញ គឺថាអាចនឹងបញ្ចប់នៅក្នុងឆ្នាំ២០១៦។ នៅពេលដែលយើងនិយាយនៅពេលនេះគឺថា អ្នកស៊ើបអង្កេតកំពុងតែធ្វើការងារស្រាវជ្រាវប្រមូលព័ត៌មានភស្តុតាងទាំងអស់នោះ។ ភស្តុតាងមួយចំនួនគឺថាអាចនឹងត្រួតស៊ីគ្នានៅភស្តុតាងដែលស្ថិតនៅក្នុងរឿងក្ដីនេះ រហូតដល់ចុងបញ្ចប់នៃសវនាការនេះយើងពិនិត្យឃើញថា ហើយយើងនឹងប្រាកដថាព័ត៌មានមួយចំនួនសហព្រះរាជអាជ្ញាគឺមានកាតព្វកិច្ចក្នុងការដាក់បង្ហាញ ទោះបីជាភស្តុតាងនោះ ឯកសារនោះជាភស្តុតាងដាក់បន្ទុក ឬក៏ដោះបន្ទុក ហើយនិងបញ្ជាក់ពីភាពជឿជាក់នៃភស្តុតាងនោះក៏ដោយ។ ហើយសហព្រះរាជអាជ្ញានៅក្នុងចុងបញ្ចប់នៃកិច្ចដំណើរការនេះ ខ្លួនមិនថាកុំឲ្យមេធាវីការពារក្ដីអាចនឹងនិយាយថា សហព្រះរាជអាជ្ញាបានលាក់ទុក ឬក៏មិនបង្ហាញឯកសារទៅដល់ភាគីទាំងអស់។ ដូច្នេះ យើងបានធ្វើជាភារកិច្ចរបស់យើង កាតព្វកិច្ចរបស់យើងៗដាក់បង្ហាញទាំងអស់ ដើម្បីឲ្យពួកគាត់បានដឹងទាំងអស់គ្នា។ បាទ ហើយភាគីអាចនឹងមានការមិនសូវសប្បាយចិត្តទៅនឹងអ្វីដែលខ្លួនថា ឯកសារចេះតែដាក់បន្ថែមៗ គិតថាសហព្រះរាជអាជ្ញាចេះតែដាក់បង្ហាញនេះ។ សូមជម្រាបថានេះជារឿងក្ដីព្រហ្មទណ្ឌអន្តរជាតិដ៏ទូលំទូលាយឯកសារវាច្រើន យើងមានភារកិច្ច និងកាតព្វកិច្ចនឹងធ្វើបែបនេះ។

[០៩:៤១:៣៣]

លោកចៅក្រមជាទីគោរព គឺថាយើងមានកាតព្វកិច្ច -- ហើយយើងនឹងគោរពទៅតាមសំណើដូចជារបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ថានៅពេលណាយើងត្រូវដាក់ ហើយពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយការបកប្រែដោយសង្ខេបទាក់ទងទៅនឹងការដ្ឋានត្រពាំងថ្ម ហើយយើងនឹង

ដាក់នៅល្ងាចនេះ ហើយពាក្យសុំ ហើយនិងសេចក្ដីសង្ខេបនឹងដាក់ជូនទៅមេធាវីការពារក្ដីនៅថ្ងៃពុធល្ងាច។ ហេតុអីមិន ឥឡូវនេះក៏ម៉េចក៏មិនសប្ដាហ៍មុនបានដាក់? ពីព្រោះថាយើងទទួលសំណើរបស់សហមេធាវីនាំតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះគឺថាលោកចៅក្រមជ្រាបហើយ គឺថាយើងត្រូវឲ្យមានការបកប្រែទាំងស្រុង ហើយសហព្រះរាជអាជ្ញាក៏ពិនិត្យមើលកំណត់ហេតុស្ដាប់ចម្លើយសាក្សីជាអត្ថិភាព បន្ទាប់មកយើងពិនិត្យពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានបកប្រែទាំងស្រុង។ ហើយដូច្នេះគឺថា យើងនឹងមើលលំដាប់ទី៣ គឺថាពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានបកប្រែសង្ខេបៗ។

ជាសេចក្ដីបញ្ចប់ ខ្ញុំសូមជម្រាបថា ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលយើងយល់ថា មានការពាក់ព័ន្ធនឹងរឿងក្ដីនេះ គឺថាយើងនឹងដាក់បង្ហាញ ឬក៏ផ្ដល់ជូនទៅមេធាវីការពារក្ដីលោកចៅក្រម ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរយៈពេលពីរសប្ដាហ៍កន្លះ ឬក៏តិចជាងហ្នឹងទាក់ទងទៅនឹងគឺថាអាចនឹងសុំការឯកភាពពីសហចៅក្រមស៊ើបអង្កេតនោះផងដែរ។

ដូច្នេះ ការអនុវត្តជាក់ស្ដែងបានបង្ហាញឲ្យឃើញថា ចៅក្រមស៊ើបអង្កេតគឺថាបានផ្ដល់សេចក្ដីសម្រេចហ្នឹងឆាប់ៗ ពីព្រោះពួកគាត់យល់អំពីសារៈសំខាន់នៃការមានព័ត៌មានឲ្យបានឆាប់រហ័សមុនពេលដែលសវនាការនេះវគ្គនេះបានបញ្ចប់។ ឲ្យភាគីអាចនឹងជំទាស់ឲ្យបានទាន់ពេល ដូចលោក លីសាក់ បានបញ្ជាក់ពីខាងចុងក្រោយហ្នឹង ការបង្ហាញឯកសារនេះនៅថ្ងៃនេះៗ គឺអាចនឹងមានគ្រប់គ្រាន់នៅថ្ងៃពុធទាក់ទងទៅនឹងត្រពាំងថ្ម។ ហើយទាក់ទងទៅនឹងបញ្ហាទាក់ទងទៅនឹងចាមនោះគឺថា ហើយសហព្រះរាជអាជ្ញាក៏បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឲ្យតុលាការមានភស្ដុតាងដ៏គ្រប់គ្រាន់ពេញលេញល្អ ហើយមេធាវីការពារក្ដីក៏មានព័ត៌មានគ្រប់គ្រាន់ដើម្បីថាតើអ្វីដែលប៉ះពាល់ទៅនឹងភាពជឿជាក់បាននៃភស្ដុតាងនេះជាបញ្ហាស្មុគស្មាញ។

[០៩:៤៥:០៩]

យើងនិយាយថាយើងធ្វើការ ១៣ថ្ងៃក្នុងមួយម៉ោង -- ១៤ម៉ោងក្នុងមួយថ្ងៃ, ១៣ម៉ោងក្នុងមួយថ្ងៃហ្នឹងគឺថា យើងត្រូវការឲ្យខ្លាំងដើម្បីពិនិត្យមើលក្នុងការកំណត់ឲ្យដឹងថា តើយើងត្រូវធ្វើដូចម្ដេច ហើយយើង -- សហព្រះរាជអាជ្ញាយើងមិនចង់ឲ្យមានការលម្អៀងក្នុងកាតព្វកិច្ចរបស់ខ្លួនក្នុងការលាតត្រដាងឲ្យភាគីមើលឯកសារ ហើយនិងភស្ដុតាងទាំងអស់ឲ្យទាន់ពេល។ ហើយនឹងជម្រាបជូនចៅក្រមឲ្យបានដឹងដូចគ្នានោះដែរ ហើយឲ្យមេធាវីការពារក្ដីបានទទួលនូវព័ត៌មានភស្ដុតាងឯកសារទាំងអស់។

ហើយបើយើងយល់ថា មានច្រើនប៉ុនណាយើងនឹងផ្តល់ឲ្យប៉ុណ្ណោះ។ ហើយខ្ញុំអស់ពេល១០នាទីហើយ ខ្ញុំអាចនឹងផ្តល់សេចក្តីលម្អិតបន្ថែមទៀតទាក់ទងទៅនឹងលក្ខណៈនៃពាក្យសុំដើមបណ្តឹងរបស់រដ្ឋប្បវេណី ដែលយើងត្រូវដាក់បង្ហាញនោះ ខ្ញុំអាចនឹងផ្តល់ជាលេខទាក់ទងទៅនឹងរឿងក្តី០០៣, ០០៤ ប៉ុន្តែលោកចៅក្រមអាចនឹងយល់ថា អាចនឹងដាក់ជូននៅក្នុងសំណើខ្លីមួយដែលយើងអាចនឹងរាយនូវលេខឯកសារទាំងអស់នោះ ហើយយើងមានឯកសារទាំងអស់ទាក់ទងទៅនឹងបញ្ហានេះគឺថាអាទិត្យក្រោយ។ រីឯទាក់ទងទៅត្រពាំងថ្ម យើងអាចនឹងផ្តល់ជូននៅថ្ងៃពុធ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ លោកសហព្រះរាជអាជ្ញា ខ្ញុំមានសំណួរមួយចំនួនដើម្បីព្យាយាមយល់នូវអ្វីដែលលោកបានលើកឡើង។ លោកបានបញ្ជាក់ថា ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានភាពពាក់ព័ន្ធនៃវគ្គដែលយើងបានពិនិត្យមើលរួចមកហើយ ដូចជា ពិសេសដូចជាត្រពាំងថ្ម និងត្រូវផ្តល់ជូនភាគីក្នុងពីពេលនេះ ចាប់ពីពេលពីរសប្តាហ៍កន្លះទៅខាងមុខ។ នៅពេលដែលលោកនិយាយអំពីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងផ្តល់ជូនភាគីនេះ តើក្នុងចំណោមនោះមានតែមួយផ្នែកទេ ឬក៏យ៉ាងម៉េចដែលនឹងត្រូវធ្វើជាសំណុំចូលដាក់នៅក្នុងសំណុំរឿងនោះ? តើលោកបានកំណត់ចំនួនពាក្យសុំតាំងខ្លួនដែលលោកចង់ស្នើសុំដាក់ចូលនៅក្នុងសំណុំរឿងជាភស្តុតាងថ្មីប៉ុន្មាន? ព្រោះថាយើងមានចំណុចពីរ។ ទី១ គឺលោកមានកាតព្វកិច្ចបង្ហាញភស្តុតាងទាំងអស់ដែលពាក់ព័ន្ធទៅភាគី ក៏ប៉ុន្តែលោកក្នុងឋានៈជាសហព្រះរាជអាជ្ញា គឺលោកមានសិទ្ធិស្នើសុំតែផ្នែកមួយចំនួនដាក់ចូលទៅក្នុងសំណុំរឿងទាំងអស់ មិនអាចដាក់ទាំងអស់បានទេ។

[០៩:៤៧:០៥]

សំណួរទី២ ពាក់ព័ន្ធនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ បើខ្ញុំស្តាប់មិនច្រឡំទេ សហមេធាវីនាំមុខធ្វើតែសំណើតែមួយគត់កាលពីព្រឹកមិញនេះ គឺសុំពិនិត្យមើលឡើងវិញនូវបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនចង់ស្នើសុំឲ្យកោះហៅមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្ម ជាពិសេសគឺឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅការដ្ឋានអាងត្រពាំងថ្ម ហើយបានស្នើសុំពេលវេលាពីរសប្តាហ៍ដើម្បីកែសម្រួលបញ្ជីនេះ។ អ្វីដែលខ្ញុំអាចយល់នោះ គឺថាកាលបរិច្ឆេទកំណត់ក្នុងការដាក់បញ្ជីពិនិត្យ

មើលឡើងវិញនោះ គឺកំណត់ដល់ថ្ងៃទី២៤ ខែសីហា។ ខ្ញុំដឹងថាកាលបរិច្ឆេទនេះ អាចប្រែប្រួល ក៏ប៉ុន្តែ ខ្ញុំគិតថានៅថ្ងៃនេះ គឺយើងមានការកំណត់សវនាការគឺនៅថ្ងៃទី០៣ -- ០២, ០៣ ខែកញ្ញា សម្រាប់ស្តាប់សក្ខីកម្មពាក់ព័ន្ធទៅនឹងផលប៉ះពាល់។ ដូច្នេះខ្ញុំគិតថាពេលវេលានេះ គឺមានផ្តល់ពេលគ្រប់គ្រាន់ឲ្យភាគីអាចត្រៀមខ្លួនបានហើយ។ តើខ្ញុំនិយាយអ៊ីចឹងត្រូវទេ?

[០៩:៤៨:២២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ពិតណាស់លោកចៅក្រម លោកយល់ច្បាស់នូវសំណើរបស់យើងហើយ គឺថាថ្ងៃទី០២, ០៣ កញ្ញានេះ យើងអត់ទាន់ដឹងទេ។ អ៊ីចឹងភាគីអាចកែតម្រូវខ្ញុំផង បើជាខ្ញុំនិយាយខុស។ យើងអត់ទាន់បានដំណឹងព័ត៌មានអីពីពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទសវនាការថ្ងៃ០២, ០៣ កញ្ញា នេះទេ។ ពិតហើយ យើងត្រូវការពេលវេលាពីរសប្តាហ៍ ដើម្បីកែសម្រួលឡើងវិញរហូតទៅដល់ថ្ងៃទី២៤ ខែសីហា គឺវាផ្តល់ពេលវេលាគ្រប់គ្រាន់ទៅដល់ភាគី ដើម្បីអាចសិក្សាទៅលើឯកសារទាំងអស់ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនៃបញ្ជីកែតម្រូវនេះ។ ខ្ញុំសូមបញ្ជាក់បន្ថែមផងដែរថា វាពាក់ព័ន្ធទៅនឹងការកំណត់សម្គាល់របស់ខ្ញុំទាក់ទងទៅនឹងសហព្រះរាជអាជ្ញា គឺថាភាគីមានសិទ្ធិដាក់សំណើទៅតាមវិធាន៨៧(៤) ហើយយើងៗអាចមានផលប្រយោជន៍របស់យើងក្នុងការដាក់សំណើរបស់យើងយោងតាមវិធាន៨៧(៤) ដែលវាពាក់ព័ន្ធទៅនឹងឯកសារចំនួនដែលកំពុងផ្តល់ជូនដោយការិយាល័យសហព្រះរាជអាជ្ញា។

[០៩:៤៩:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ លោកចៅក្រម ឡាវែន៍ បានឆ្លើយទៅ -- ឆ្លើយទៅសំណួរលោកចៅក្រម ឡាវែន៍។ ទាក់ទងទៅនឹងការជូនដំណឹងដែលសហព្រះរាជអាជ្ញាបានដាក់ជូន គឺឯកសារ E319 -- E319 វិធីសាស្ត្ររបស់យើងពាក់ព័ន្ធទៅនឹងជនរងគ្រោះនោះគឺថា វិធីសាស្ត្រយើងត្រូវបានកែប្រែនៅកន្លែងមួយចំនួន ដោយយោងទៅលើអ្វីដែលមេធាវីរបស់លោក ខៀវ សំផន និង នួន ជា បានលើកឡើងនៅថ្ងៃចន្ទ ទី២៧ ហើយសារៈសំខាន់នៃសេចក្តីថ្លែងការណ៍នេះគឺថា លើកលែងតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ជូនទាក់ទងទៅនឹងឯកសារចំនួន៨៤ ពាក់ព័ន្ធទៅនឹង -- ហើយខ្ញុំ

គិតថាផ្នែករបស់យើងនេះ គឺថាវាផ្នែកពាក់ព័ន្ធទៅនឹងភស្តុតាងដោះបន្ទុក។ មេធាវីការពារក្តីមិនចង់ប្រើប្រាស់នូវឯកសារទាំងអស់នោះទេ ពីព្រោះថាវាគ្រប់គ្រាន់ហើយ។ អ្វីដែលគ្រប់គ្រាន់គឺចាត់ទុកគ្រប់គ្រាន់ហើយ ពីព្រោះមានឯកសារច្រើនសន្ធឹកសន្ធាប់ហើយ។ ដើម្បីដោះស្រាយទៅនឹងកុំឲ្យមេធាវីការពារក្តីនេះមានបន្ទុកត្រូវអានឯកសារនេះច្រើនពេក នីតិវិធីថ្មីគឺថាឥឡូវនេះយើង ក្រៅពីត្រពាំងថ្ម យើងនឹងផ្តល់នូវបញ្ជីឯកសារដើម្បីធ្វើការបង្ហាញនូវឯកសារដែលទំនងជានឹងយកមក។

[០៩:៥២:១៣]

ដោយអនុវត្តទៅតាមវិធាន៨៧(៤) ដូច្នេះវាអាស្រ័យទៅលើមេធាវីការពារក្តី ថាតើពួកគាត់ត្រូវអានឯកសារទាំងអស់នេះឬក៏យ៉ាងណា? ហើយកាលពីមុននោះ ក្នុងការបង្ហាញឯកសារជូនតុលាការមិនមានការបញ្ជាក់ថាតើវិធាន៨៧(៤) នេះ អាចត្រូវយកមកអនុវត្តទៅលើឯកសារជាក់លាក់ណាបានឬក៏អត់នោះទេ។ ដូច្នេះដើម្បីបន្ថយនូវបន្ទុករបស់មេធាវីការពារក្តី ឧទាហរណ៍ថាមានឯកសារ ៥០ ឬក៏ចំនួនណាមួយ គឺថា ១០ ឬក៏ ប្រាំ ឬក៏ -- យើងនឹងផ្តល់ជូននូវចំនួនតិចតួចទេ ដើម្បីធ្វើយ៉ាងណាកុំឲ្យមេធាវីការពារក្តីនេះចំណាយពេលវេលាច្រើនពេកក្នុងការអានឯកសារទាំងអស់នេះ។ នេះគឺជានីតិវិធីដែលយើងដាក់ជូនឯកសារជាបណ្តើរៗនេះ។

ហើយភស្តុតាងពាក់ព័ន្ធទៅនឹងត្រពាំងថ្មនេះ គឺការញែកឲ្យដាច់ពីគ្នានៅក្នុងឯកសារទាំងអស់នេះនៅក្នុងពាក្យសុំដែលដាក់នៅថ្ងៃនេះ គឺថាមិនបានញែកឲ្យច្បាស់ពីគ្នានៅឡើយទេ ប៉ុន្តែអ្វីដែលយើងខ្ញុំនឹងធ្វើ ហើយអ្វីដែលយើងខ្ញុំអាចនឹងធ្វើបាននោះគឺ នៅចុងសប្តាហ៍នេះ យើងអាចធ្វើការប៉ាន់ប្រមាណធ្វើការដាក់ឯកសារជូនទៅតុលាការ។ យើងបានពិនិត្យមើល និងកែប្រែប្រហែលជា ១០ភាគរយមកហើយ។ ដូច្នេះពាក់ព័ន្ធទៅនឹងការដាក់បង្ហាញឯកសារទាំងអស់នេះគឺថាយើងធ្វើឡើងនៅក្នុងរយៈពីរបីសប្តាហ៍ខាងមុខទៀត។ យើងនឹងធ្វើការញែកពីគ្នាឲ្យបានច្បាស់លាស់នូវអ្វីដែលមេធាវីការពារក្តីបានលើកឡើង។ ចំណុចក្រោយទាក់ទងទៅនឹងវិធាន ៨៤(៤) -- ៨៧(៤)។ ពាក្យសុំនៅចំពោះមុខតុលាការក្នុងការបង្ហាញឯកសារនោះ គឺថាមេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំពេលវេលាបន្ថែមទៀតទោះបីមិនដឹងថាខ្លួនត្រូវជំទាស់ឯកសារឬក៏យ៉ាងនោះទេ ប៉ុន្តែស្នើពេលវេលាបន្ថែមដើម្បីអានឯកសារទាំងអស់នេះ។ ទាំងមេធាវីការពារក្តី ខៀវ សំផន និង នួន ជា គឺថាស្នើសុំពេលវេលបន្ថែមលើអ្វីដែលវិធានផ្ទៃក្នុងបានអនុញ្ញាត ដើម្បីធ្វើការវាយតម្លៃទៅលើឯកសារទាំងអស់នេះឲ្យបានត្រឹមត្រូវ ដែលពួកគាត់អាចទាមទាររយៈពេលពីបីសប្តាហ៍ទៅមួយខែឯនោះ។ ដូច្នេះ យើងខ្ញុំសូមជំទាស់ចំពោះសំណើសុំ

បន្ថែមពេលវេលានេះ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀត សូមជូនវេទិការឲ្យលោកមេធាវីការពារក្ដីលោកជនជាប់ចោទលោក នួន ជា។ សូមលោកមេធាវី កូប៉េ សូមអញ្ជើញ!

[០៩:៥៥:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកចៅក្រម សហការីទាំងអស់។

ខ្ញុំបានស្ដាប់យ៉ាងយកចិត្តទុកដាក់ ទាំងដើមបណ្ដឹង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាសហព្រះរាជអាជ្ញា ប៉ុន្តែខ្ញុំខ្លាចក្រែងខ្ញុំតាមមិនបានជិតដល់។ ខ្ញុំនៅទីនេះគ្រាន់តែសុំរំឭកទៅដល់ បាទ ខ្ញុំបានរំឭកពីរសប្ដាហ៍មុនហើយនូវការពិភាក្សាស្រដៀងគ្នានេះដែរ នៅពេលនោះគឺថាយើងមានការជំទាស់តវ៉ាក្នុងការអានឯកសារជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាងហាសិប ដែលនាំឲ្យអង្គជំនុំជម្រះសម្រេចផ្អាកសវនាការស្ដាប់សក្ខីកម្មសាក្សីអស់មួយសប្ដាហ៍កន្លងមកនេះ។ មិនមែនសម្រាប់តែសាក្សីពីរនាក់ពីខាងដើមនោះទេ ហើយឥឡូវនេះគឺមានការពិភាក្សាគ្នាជាថ្មីទៀត ក្នុងនោះមានចម្លើយមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលឯកសារទាំងអស់នោះមានតែជាភាសាខ្មែរ អាចមានជាភាសាអង់គ្លេសជាភាសាបារាំងខ្លះដែរ។ ឥឡូវនេះ យើងកំពុងតែប្រឈមមុខទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រមាណ ២០០ច្បាប់ទៀត ដែលខ្ញុំដឹងថាពាក្យសុំទាំងអស់នោះ គឺថានឹងយកមកដាក់ចំពោះមុខអង្គជំនុំជម្រះដើម្បីប្រើប្រាស់ជាភស្តុតាង។ ហើយយើងត្រូវតែអាននូវឯកសារទាំងអស់នេះ មិនមែនពាក់ព័ន្ធទៅលើការតម្លៃទៅលើភស្តុតាងបែបនោះប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ត្រូវអានដើម្បីមើលឲ្យដឹងសិនថាតើពាក្យសុំទាំងអស់នេះមានព័ត៌មានពាក់ព័ន្ធទៅនឹងសាក្សីដែលចូលខ្លួនមកចំពោះមុខតុលាការសប្ដាហ៍នេះ ក៏ដូចសប្ដាហ៍ក្រោយៗទៀតដែរឬក៏អត់។

[០៩:៥៧:១១]

ហើយសេចក្ដីសម្រេចពីខាងដើមរបស់អង្គជំនុំជម្រះ គឺថាៗវាមានលទ្ធភាពថា ការផ្អាកសវនាការគឺថា សាក្សីនេះក៏អាចហៅមកវិញបានដែរៗ ដោយសារហេតុផលទាំងអស់នេះឯង។ ប៉ុន្តែខ្ញុំគិតឃើញថាក្នុងការអនុវត្តជាក់ស្ដែង គឺថាស្ថានភាពដែលមិនអាចដំណើរការទៅបានទេ ពេលខ្លះគឺថាមានការស្រង់តែផ្នែកតូចមួយចេញពីព័ត៌មានរបស់សាក្សី ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ យើងខ្ញុំស្ថិតនៅ

ជំហរមួយដែលថា ឯកសារដែលអាចពាក់ព័ន្ធខ្លះកំពុងតែរង់ចាំពួកយើង ដើម្បីឲ្យយើងខ្ញុំមានពេលអាន និងពិនិត្យមើលឯកសារទាំងអស់នេះ ហើយរសៀលនេះ ក៏យើងចាប់កផ្ដើមជាមួយសាក្សីមកពីទំនប់ការដ្ឋានលើកទំនប់នេះមួយដែរ។ ដូច្នេះ ខ្ញុំមិនដឹងថាតើខ្ញុំអាចយល់នូវភាពខុសគ្នាដែលអ្វីដែលយើងបានពិភាក្សាពីរសប្ដាហ៍កន្លងមកហើយ ដោយសារតែឯកសារទាំងអស់នោះ គឺថាអាចនឹងយកមកដាក់ចំពោះមុខអង្គជំនុំជម្រះដោយអនុលោមទៅតាមវិធាន៨៧(៤)។ ប៉ុន្តែយើងខ្ញុំតែងតែនៅជួបស្ថានភាពមួយដែលថា យើងខ្ញុំក៏ត្រូវតែមានលទ្ធភាពពិនិត្យមើលឯកសារទាំងអស់នេះ ថាតើឯកសារទាំងអស់នេះមានព័ត៌មានពាក់ព័ន្ធទៅនឹងសាក្សីដែលចូលខ្លួនមកចំពោះអង្គជំនុំជម្រះនៅសប្ដាហ៍ខាងមុខនេះដែរ ឬក៏អត់។ ការណ៍ដែលខ្ញុំលើកឡើងយ៉ាងដូច្នេះ គឺថាយើងគួរតែបន្តស្ដាប់សក្ខីកម្មសាក្សីទាក់ទងទៅនឹងការដ្ឋានដែលទំនប់មួយនេះបាន ហើយដូចយើងខ្ញុំលើកឡើងខាងដើមដែរ ថាតើយើងៗរក្សាទុកសាក្សីមួយចំនួនពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្មមួយនេះ ឬក៏អត់ ដើម្បីរង់ចាំការបញ្ចប់នូវសំណុំរឿងដំណើរការស៊ើបសួរសំណុំរឿង ០៣ និង ០៤។ ហើយវគ្គបន្ទាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិចាម ដែលសាក្សីនៅក្នុងរឿងនេះគឺថាត្រូវបានជ្រើសរើស ហើយយើងក៏មិនទាន់បានទទួលដំណឹងថាសាក្សីណាដែលនឹងចូលខ្លួនមកបង្ហាញអំពីការប្រព្រឹត្តទៅលើជនជាតិចាមនេះ។

[០៩:៥៩:៤៣]

ខ្ញុំយល់ឃើញថា ស្ថានភាពទាំងនេះជាស្ថានមួយលំបាកណាស់ ការដែលយើងផ្ដោតទៅលើលំហូនៃភស្តុតាងថ្មីៗនេះមក ប្រសិនណាជាយើងបន្តផ្នែកនេះទៅមុខទៀត ពាក់ព័ន្ធទៅនឹងការដ្ឋាន ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០៣ និង០៤ ដែលមិនទាន់ស៊ើបសួរបញ្ចប់នៅឡើយនោះ។ ដូច្នេះ សំណួស្របច្បាប់នោះ គឺថាអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវបញ្ហានេះបាន។ ដូច្នេះខ្ញុំយល់ឃើញថា យើងគួរតែបន្តពិភាក្សាតទៅទៀត សួរដេញដោលតទៅទៀត នៅរយៈពេលពីរបីសប្ដាហ៍ខាងមុខនេះ។

សូមអរគុណច្រើន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់គ្នា។ យើងកំពុងតែស្ថិតនៅចំពោះមុខការពិភាក្សាដែលហួសពីការសន្ទនាគ្នាកន្លងមក ហើយអ៊ីចឹងវាកើត បង្កើតឲ្យមានបញ្ហានីតិវិធីទាក់ទងទៅនឹងផលប្រយោជន៍នៃការបញ្ជូនឯកសារពីសំណុំរឿង០៣, ០៤ មកសំណុំរឿង០២នេះ។ ដើម្បីនិយាយតាមលំដាប់លំដោយ ខ្ញុំសូមឆ្លើយទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទង

ទៅនឹងការសុំពន្យារពេលវេលា និងការពិនិត្យបញ្ជីដើមបណ្ដឹងរដ្ឋប្បវេណីឡើងវិញ ដែលគាត់ចង់បាន -- ចង់បង្ហាញនៅក្នុងផ្នែកនេះ។

យើងមានគោលជំហរយល់របស់គាត់ ហើយនិងយល់អំពីផលប៉ះពាល់ថា ការដែលចេះតែផ្ទេរឯកសារមកច្រើនដូច្នេះនេះ គឺថាធ្វើឲ្យទំហំការងារនោះកាន់តែកើនឡើង ហើយយើង ដូច្នេះយើងអាស្រ័យលើចៅក្រមក្នុងការកំណត់ពេលវេលាបន្ថែម ហើយនិងធ្វើកាលវិភាគទៅតាមសំណើរបស់គាត់។ នេះជាចម្លើយទី១ ដែលខ្ញុំអាចផ្ដល់ជូន។

[១០:០១:៥៥]

ទាក់ទងនឹងចំណុចទី២ កាតព្វកិច្ចនៅក្នុងការផ្សព្វផ្សាយដូចដែលលោកព្រះរាជអាជ្ញានិយាយថា ជាការកត់សម្គាល់នោះ ហើយយើងត្រូវ -- គាត់ត្រូវតែសរសេរជាលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់ បានវែង បានលម្អិត។ ឥឡូវខ្ញុំសូមការធ្វើការបញ្ជាក់មួយទៀតថា ខាងព្រះរាជអាជ្ញាហ្នឹង និយាយថា ឥឡូវយើងស្ថិតនៅក្នុងសំណុំរឿងស្មុគស្មាញណាស់។ ខ្ញុំយល់ ហើយយើងប្រហែលជាមានទស្សនៈខុសគ្នាទាក់ទងទៅនឹងការផលវិបាក ក្នុងការបញ្ជូនឯកសារមកមិនចេះ មិនចេះហើយនេះ យើងៗមិនមែននិយាយថាយើងមានបញ្ហាក្នុងការអានឯកសារទាំងអស់នោះឲ្យចប់នោះទេ ក៏ប៉ុន្តែយើងមានបញ្ហាក្នុងការរៀបចំការងាររបស់យើង។ ខ្ញុំសូមបញ្ជាក់ថា យើងស្ថិតនៅក្នុងដំណាក់កាលមួយដែលត្រូវការត្រៀមលក្ខណៈវិភាគចម្លើយរបស់សាក្សីសព្វបែបយ៉ាង ដើម្បីឲ្យដឹងថា តើអ្វីសំខាន់សម្រាប់កូនក្ដីរបស់យើង អ្វីដែលសំខាន់របស់យើង។ យើងមិនអាចធ្វើម្ដង ធ្វើនេះផង ធ្វើនោះផង ការពារក្ដីវគ្គនេះផង មើលអ្វីផ្សេងផងនោះទេ។

ខ្ញុំសូមកត់សម្គាល់ថា មានការវិវត្តន៍ខាងព្រះរាជអាជ្ញា គោលជំហររបស់ព្រះរាជអាជ្ញា ព្រោះថាលោក វីណ្លៀម ស្មីត គាត់និងសហភាតារបស់គាត់ ឌេល លីសាក់ បាននិយាយថា មានការផ្ដល់ឯកសារមកបន្តបន្ទាប់ ក៏ប៉ុន្តែមិនមានការផ្លាស់ប្ដូរអ្វីនោះទេ។ អ៊ីចឹងត្រង់នេះ ខ្ញុំដូចជាមិនយល់ទេ ព្រោះថាគាត់អាចនិយាយស្រួលអ៊ីចឹងបាន ក៏ប៉ុន្តែឯកសារទាំងអស់នេះ គឺថាមកពី០៣, ០៤ ច្រើន ហើយភាគីខាងការពារក្ដី ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីនោះ ហើយយើងមានគោលជំហរផ្សេង ព្រោះថាយើងមិនអាចពិគ្រោះឯកសារនោះបាននោះទេ ទាល់តែគេផ្ដល់ឯកសារមកបានយើងដឹង។ អ៊ីចឹងការងាររបស់យើងគឺថាការពារក្ដី ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណី គឺថាមានការងារហ្នឹង គឺថាទាល់តែគេបញ្ជូនឯកសារមកបានចាប់ផ្ដើមធ្វើការបាន។ អ៊ីចឹងឯកសារទាំងអស់នេះ វា យើងត្រូវតែវិភាគ ហើយមាន

ផលប៉ះពាល់ទៅលើយុត្តិសាស្ត្រក្នុងការពារកូនក្ដីរបស់យើង។ អ៊ីចឹងខ្ញុំសូមកត់សម្គាល់ចំណុចនេះ។

[១០:០៤:២៣]

ចំណុចទី៣ គឺយើងត្រូវតែនិយាយអំពីចំណុចនេះម្ដងទៀត ព្រោះថានៅក្នុងយុត្តិសាស្ត្រអន្តរជាតិរហូតដល់ពេលនេះ មិនដែលមានបញ្ហាចំពោះសាក្សីដែលគេនឹងកោះហៅមកនោះទេ ឬក៏សាក្សីដែលបានមកហើយ ហើយកោះហៅម្ដងទៀតនោះទេនៅពេលដែលមានចំណុចពាក់ព័ន្ធនោះ។ អ៊ីចឹងកាលណាមានករណីដូច្នេះ យើងអាចផ្ទេរ ឬក៏ដាក់បញ្ជូនឯកសារនោះចូលបាន។ ក៏ប៉ុន្តែអ្វីដែលអាចជាភស្តុតាងដោះបន្ទុករបស់ជនជាប់ចោទនោះ វាជារឿងធម្មតាទេ ដែលជាការសំខាន់ណាស់ដែលយើង ក៏ដូចជាភាគីផ្សេងទៀតត្រូវតែដឹង។ មានចំណុចមួយទៀត គឺថាសហព្រះរាជអាជ្ញាគាត់មានគំនិតថ្មីមួយ បើយើងធៀបទៅនឹងយុត្តិសាស្ត្រនោះ គឺថានៅក្នុងដំណើរការនីតិវិធីមួយ គឺមានការស៊ើបអង្កេត។ យើងបាននិយាយអង្គាល់ពីសវនាការថ្ងៃមុនហើយ គឺថាមានការស៊ើបអង្កេតកំពុងតែធ្វើ។ មិនមែនព្រះរាជអាជ្ញាជាអ្នកធ្វើការស៊ើបអង្កេតខ្លួនឯងទេ មិនមែនជាប្រព័ន្ធអាគីសាត័រទេ។ អ៊ីចឹងមានការពារក្ដីនោះអាចធ្វើលិខិតសុំកិច្ចស៊ើបអង្កេត ធ្វើអី ហើយនេះយើង តែក្នុងបរិបទយើងនេះ យើងអត់មានលទ្ធភាពអីធ្វើអ៊ីចឹងទាល់តែសោះ។

[១០:០៥:៥៤]

អ៊ីចឹងក្នុងករណីដែលមានសាក្សីមួយចំនួន ដែលថាមិនបានមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២នេះ ហើយយើងៗអត់ដឹងរឿងអ្វីទាំងអស់ចំពោះគាត់ ពីព្រោះថាក្នុងលក្ខខណ្ឌនេះយើង -- ពីព្រោះថាយើងមិនបានដឹងកាលដែលក្នុងដំណាក់កាលស៊ើបអង្កេតនោះ យើងមិនបានដឹងរឿងរ៉ាវទាំងអស់នេះ។ ក៏ប៉ុន្តែទាក់ទងទៅនឹងការផលប៉ះពាល់នៃការបញ្ជូនឯកសារពីសំណុំរឿង០៣, ០៤ មកនេះហ្នឹង គឺថាការងារត្រៀមលក្ខណៈរបស់យើងហ្នឹង វាជួបឧបសគ្គខ្លាំង វាជាការសំខាន់ណាស់ ព្រោះថាយើងធ្វើដូចប្រញាប់ប្រញាប់ពភីងរហូត យើងមិនអាចត្រៀមលក្ខណៈគ្រប់គ្រាន់បានទេ។ យើងមានបញ្ហាចោទជាច្រើនទាក់ទងនឹងឯកសារថ្មីទាំងអស់នេះ។ យើងមិនអាច យើងមិនដឹងថាចោទសំណួរយ៉ាងម៉េចផង ព្រោះថាយើងមិនបានវិភាគឯកសារហ្នឹង យើងធនធានមនុស្សយើង ក៏យើងពិបាក ក៏មានតិចតួច ហើយមួយថ្ងៃមានតែ២៤ម៉ោងទេ បើគិតពីកម្លាំងមនុស្សនោះ មិនអាចធ្វើទៅបានទេ ធ្វើការងារឲ្យបានសមស្របនេះ។ នេះជាអ្វីដែលខ្ញុំចង់លើកឡើង គឺថាទាក់ទងទៅនឹងការដែលដាក់ឯកសារថែមមករហូតនេះ គឺថាត្រូវតែពិភាក្សាគ្នាឲ្យលម្អិតល្អន់ ហើយដើម្បីឲ្យដឹងថាតើមានផលប៉ះពាល់យ៉ាងណាដែរ។

ដូចព្រះរាជអាជ្ញានិយាយអម្បាញ់មិញហ្នឹង គឺថាមានឯកសារ២០០ជាងទៀត ដែលនឹងបញ្ចូលមក។ ខ្ញុំមិនដឹងថាផលប៉ះពាល់លើលោក ខៀវ សំផន នោះប៉ុនណានោះទេ។ អ៊ីចឹងខ្ញុំសូមឆ្លើយជូនទៅគាត់ថា នេះវាដឹងថាផលប៉ះពាល់នោះធំធេងណាស់ ធ្ងន់ធ្ងរណាស់។ ខ្ញុំសូមបញ្ចប់ធ្វើការកត់សម្គាល់ខ្ញុំនៅត្រឹមណេះ ក៏ប៉ុន្តែបើសិនជាមានការប្រែប្រួល ការដោះដូរទៅមុខទៀត ដូចលោកមេធាវី កូប៉េ បានលើកឡើងអ៊ីចឹង គឺថាយើងនឹងសម្របសម្រួល កែប្រែទំហំការងាររហូតនៅក្នុងក្រុមការងាររបស់យើង។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះគិតអំពីការភាពបត់បែននេះផង ហើយយើងតែងតែមានភាពបត់បែន ក៏ប៉ុន្តែសូមឲ្យអង្គជំនុំជម្រះជួយពិចារណាថ្លឹងថ្លែងលើទំហំការងារនេះផង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

[១០:០៨:៣៥]

**លោក វីល្លៀម ស្មីត៖**

លោកប្រធានខ្ញុំយល់ហើយ គឺថាចង់ឲ្យខ្ញុំលើកឡើងសង្ខេប ដូច្នេះខ្ញុំលើកឡើងសង្ខេបទេ។ សូមឆ្លើយតបពីរបីចំណុចទាក់ទងទៅនឹងមេធាវីការពារក្តីលោក នួន ជា ដែលបានស្នើសុំឲ្យផ្អាក គឺថាចម្លើយពាក់ព័ន្ធទៅនឹងការដ្ឋានត្រពាំងថ្មរហូតដល់បញ្ចប់សំណុំរឿង០០៣ និងការស៊ើបអង្កេត០៣ និង០៤សិន គឺថាបង្អកចម្លើយពាក់ព័ន្ធទៅនឹងបញ្ហានេះរហូតទាល់តែសំណុំរឿង០៣, ០៤ បញ្ចប់។ តើចង់មានន័យថាដូចម្តេច ការដែលស្នើសុំឲ្យផ្អាកយ៉ាងហោចណាស់ក៏រយៈពេលមួយឆ្នាំទៀតដែរ។

យើងខ្ញុំបានទទួលចម្លើយ បី ទៅ ប្រាំ ទៅ ១២ សហចៅក្រមស៊ើបអង្កេតជារៀងរាល់សប្តាហ៍ ដែលត្រូវបន្តស៊ើបអង្កេតរហូត ប្រហែលជាដល់ឆ្នាំក្រោយឯណោះ។ ដើម្បីឲ្យសវនាការនេះឿនលឿនទៅមុខបាន ក៏ត្រូវឲ្យសវនាការមួយដែលមានយុត្តិធម៌ និងមានភាពត្រឹមត្រូវ ឲ្យមេធាវីការពារក្តីស្នើសុំដាក់ព័ត៌មានពាក់ព័ន្ធទៅនឹងព័ត៌មានដែលអាចទទួលបាន។ ខ្ញុំយល់ឃើញថា សំណើសុំបែបនេះនឹងមិនអាចដំណើរការទៅបានទេ។ ហើយទាក់ទងទៅនឹងមេធាវី ចំណុចរបស់មេធាវីការពារក្តី ខៀវ សំផន គឺថាចំណុចមួយច្បាស់ហើយ។ មេធាវីការពារក្តី សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាចៅក្រម យល់ហើយថាសហព្រះរាជអាជ្ញាមានកាតព្វកិច្ចបង្ហាញភស្តុតាងដ៏ទូលំទូលាយបែបនេះ។ យើងមិនមានជម្រើសអ្វីក្រៅពីនេះទេ។ អ្វីដែលចៅក្រមបំពេញកិច្ចការរបស់ខ្លួន មេធាវីការពារក្តីបំពេញកិច្ចការរបស់ខ្លួន សហមេធាវីនាំមុខបំពេញកិច្ចការរបស់ខ្លួន ជារឿងរៀងៗខ្លួន

ប៉ុន្តែនេះជាកាតព្វកិច្ចរបស់យើងខ្ញុំ ពីការិយាល័យសហព្រះរាជអាជ្ញាដែលត្រូវបង្ហាញភស្តុតាង។ ប្រហែលជាយើងអាចជួបជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ ដើម្បីកំណត់អំពីពេលវេលា និងវិធីសាស្ត្រពាក់ព័ន្ធទៅនឹងការស្នើសុំសិទ្ធិអំណាច ឲ្យបង្ហាញភស្តុតាងពីសហចៅក្រមស៊ើបអង្កេត។ ចុះដំណោះស្រាយពាក់ព័ន្ធទៅនឹងមេធាវីការពារក្តីវិញ យើងមិនអាចបន្តធ្វើការជជែកតវ៉ាគ្នារាល់សប្តាហ៍បែបនេះបានទេ។ នៅពេលដែលយើងត្រូវបង្ហាញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រៅពីផ្នែកណាមួយ ដែលយើងមិនទាន់មានការបកប្រែសង្ខេបជាភាសាអង់គ្លេសហើយនោះ ដោយសារតែការកកស្ទះបែបនេះ គឺថាយើងត្រូវតែបង្ហាញប្រចាំសប្តាហ៍នៅពេលណាដែលយើងទទួលបានចម្លើយសាក្សី។ ហើយយើងខ្ញុំវាមានការត្រេកអរណាស់ក្នុងការសហការជាមួយតុលាការ ក៏ដូចជាមេធាវីការពារក្តី ដើម្បីដំណើរការឲ្យបានឆឿនលឿនទៅមុខ។ ការពន្យារសវនាការនេះ គឺថាវាជាការមួយមិនត្រឹមត្រូវដោយសារយើងមានពាក្យសុំតាំងខ្លួនប្រហែលជាទៅដល់ ៤០០០ច្បាប់ ឯណោះច្រើនណាស់ពាក់ព័ន្ធទៅនឹងសាក្សីដែលត្រូវចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះនៅសប្តាហ៍ក្រោយៗនេះ។ សូមអរគុណ។

[១០:១២:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំមានសំណួរតូចមួយសួរទៅលោកសហព្រះរាជអាជ្ញា។ យើងអាចកត់សម្គាល់ឃើញថាផ្នែកជំនុំជម្រះសំណុំរឿង០០២ យើងនេះទេ ជាពិសេសទាក់ទងនឹងផ្នែកត្រពាំងថ្មនោះ វាទាក់ទងនឹងការបញ្ចូលឯកសារថ្មីពីសំណុំរឿង០៣, ០៤ មក។ យើងត្រូវពិនិត្យវគ្គផ្សេងៗទៀតនៃសំណុំរឿង ០០២ យើងនេះ ឧទាហរណ៍ដូចជាទាក់ទងទៅនឹងក្រុមជាក់លាក់ ដូចជាជនជាតិចាម ជនជាតិវៀតណាម ហើយនិងអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ឬក៏ប្រធានបទផ្សេងទៀតដូចជាមន្ទីរស-២១ ជាដើម។ តើលោកអាចជម្រាបជូនតុលាការបានដែរទេថាតើចំពោះវគ្គផ្សេងទៀត នៃសំណុំរឿង០០២ យើងនេះដែលនឹងត្រូវយកមកដេញដោលនេះ តើនឹងមានផលប៉ះពាល់ដែរឬទេ? យើងអាចប្រមើលថានឹងមានឯកសារច្រើនមកទៀតនឹងដាក់បញ្ចូលបន្តៗមកទៀតទៅភាគី ហើយនិងមានការដាក់សំណើថ្មីទៀត ដែលសុំបញ្ចូលឯកសារទាំងអស់នេះមកធ្វើជាភស្តុតាងថ្មី។ វាជាការសំខាន់ណាស់សម្រាប់យើងពីព្រោះថាយើងត្រូវមានទស្សនវិស័យវែងឆ្ងាយ ពីព្រោះថាសំណុំរឿងយើងនេះវែងណាស់ ហើយមានផ្នែកជាច្រើន

ដែលត្រូវយកមកពិភាក្សាដេញដោល។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ពីខាងដើមនោះគឺថា ខ្ញុំគប្បីតែដាក់សារណាជាលាយលក្ខណ៍អក្សរ ប៉ុន្តែខ្ញុំសង្ខេបជូន។ អ្វីដែលយើងបានដឹងទាក់ទងទៅនឹងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ពាក្យសុំនោះ គឺថាអាចនឹងកាត់បន្ថយមួយចំនួនច្រើន ជាពិសេសទាក់ទងទៅនឹងអាងត្រពាំងថ្ម។ នៅថ្ងៃពុធ ហើយនិងថ្ងៃនេះ ហើយយើងនឹងជូនដំណឹងមេធាវីការពារក្តីនឹងទទួលបាន៣១ ទាក់ទងទៅនឹងចាម ហើយនិងសេចក្តីសង្ខេបដែលពាក់ព័ន្ធ។ បន្ទាប់មកយើងនឹងដកចេញឲ្យបានឆាប់ៗ ហើយពីចំណុចហ្នឹងតទៅទាក់ទងទៅនឹងនៅក្នុងរឿងក្តី០០៤ ពីចំណុចហ្នឹងតទៅ ហើយយើងសង្ឃឹមថាក្នុងរយៈពេលពីរសប្តាហ៍ យើងនឹងបានការអនុញ្ញាតដើម្បីឲ្យ -- បាទ គឺពាក្យសុំទាក់ទងទៅនឹងអ្នករដ្ឋការលន់ នល់ ១០៣ ហើយនិងអាពាហ៍ពិពាហ៍ដោយបង្ខំ១០២ ហើយនិងក្រាំងតាចាន់៦០ បាទ ហើយនិង៤៧ ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើវៀតណាម ហើយ១០ទាក់ទងទៅនឹងស-២១, ប្រាំមួយ គឺទំនប់១មករា, ពីរ កំពង់ឆ្នាំង មួយត្រាំកក់។ បាទ ទាក់ទងទៅនឹងរឿងក្តី០០៤ បាទ ១៩ទាក់ទងទៅនឹងការដ្ឋានកំពង់ឆ្នាំង។ បាទទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាម គឺថាយើងនឹង -- ហើយ៧២ លន់ នល់ ហើយ ៦២ វៀតណាម ហើយ៤២ក្រាំងតាចាន់, ១៤ -- ៧ បាទ ហើយនិង១៣ ស-២១ ហើយលេខទាំងអស់នេះ គឺទាក់ទងទៅនឹងពាក្យសុំដែលយើងបានពិនិត្យមើល ដែលអាចទាក់ទងទៅមានបញ្ហា ទាក់ទងទៅនឹង ហើយ-- សរុបរឿងក្តី០០៣ គឺថា ប្រហែលជាៗ ២២១ពាក្យសុំ ហើយយើងមិនដាក់ទុក -- ដាក់បញ្ចូលជាភស្តុតាងទេ គឺថានេះគឺជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់បង្ហាញ។

[១០:១៦:៣៧]

នៅក្នុងរឿងក្តី០០៤ សរុប រួមទាំងត្រពាំងថ្មផងដែរ គឺមានពាក្យសុំ៦៥០ ហើយទាក់ទងទៅនឹងវគ្គនៅពេលអនាគត ហើយនិងវគ្គដែលកន្លងរួចមកហើយដែរនៃសវនាការ។ សូមជម្រាបលោកចៅក្រមថា យើងចង់បានផ្លូវឲ្យច្បាស់ គឺថាយើងចង់បានដូចគ្នាទាក់ទងទៅនឹងការបង្ហាញឯកសារនេះ គឺថាយើងត្រូវមានទស្សនៈឲ្យច្បាស់ ដូចជាមេធាវី ខៀវ សំផន លោកបានលើកឡើងអ៊ីចឹង។ ហើយដូច្នេះគឺថា យើងមិនអាចបង្គាប់ ឬក៏ត្រួតត្រាអ្វីទៅលើការស៊ើបអង្កេតនៅក្នុងរឿងក្តី០០៣, ០០៤ ទេ មិនដឹងថាគេសម្រេចពេលណា ធ្វើប៉ុន្មាននោះទេ។ ដូច្នេះ ចំពោះយើងវិញទាក់ទងទៅនឹងការដាក់បង្ហាញឯកសារក្នុងរយៈពេលពីរបីថ្ងៃ ឬក៏ពីរបីសប្តាហ៍ទៅមុខ គឺថាយើងត្រូវការបានការអនុញ្ញាតពីសហចៅក្រមស៊ើប

អង្កេត ហើយនិងពិនិត្យមើលថាតើវានៅកកស្ទះប៉ុនណា ហើយយើងដាក់បង្ហាញដោយសហព្រះរាជអាជ្ញាទៅទៀត ហើយហ្នឹងក៏ចេះតែអនុវត្តទៅមុខតាមប្រព័ន្ធមួយ ហើយយើងក៏យល់ស្របជាមួយមេធាវីការពារក្តី យើងក៏ត្រូវពិភាក្សាជាមួយគាត់ ថាតើលោកចង់ឲ្យយើងដាក់បង្ហាញម្តងក្នុងមួយអាទិត្យ ឬក៏ពីរសប្តាហ៍ម្តង។ នេះគឺយើងមានការជជែកគ្នាជាបច្ចេកទេសបែបនេះគឺថាអាចល្អ ហើយយើងក៏យើងចង់ដឹងថា តើពួកគាត់ចង់ទទួលឯកសារហ្នឹងដោយរបៀបណា។

បាទ សូមអរគុណលោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណ ដែលបានឆ្លើយបំភ្លឺ។ លោកបានផ្តល់ការបំភ្លឺទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែខ្ញុំចង់ដឹងថា តើលោកដឹងថាស្ថានភាព -- ផ្តល់ស្ថានភាពទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនផ្សេងទៀតទេ? ខ្ញុំដឹងថាវាការស្មុគស្មាញណាស់ ព្រោះថាឥឡូវនេះមានការស៊ើប -- កំពុងតែស៊ើបអង្កេត ហើយមានសាក្សីផ្សេងទៀតដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅទីនេះ ហើយនិងដែលបានមកហើយ។ អ៊ីចឹងខ្ញុំសួរលោកថា ដល់ពេលនេះៗ តើលោកដឹងថា សម្រាប់ប្រភេទឯកសារផ្សេងទៀតនេះ ក្រៅពីឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី លោកដឹងថាឯកសារទាំងអស់នោះស្ថិតក្នុងស្ថានភាពណាដែរឬទេ?

[១០:១៩:០៣]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំជូនព័ត៌មានមួយចំនួន។ ចំណុចទី១ គឺថាដើម្បីបញ្ចប់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅបញ្ហានេះ នៅក្នុងរឿងក្តី០០៤ បាទមានពាក្យសុំប្រហែលជា៧២០។ នៅក្នុងរឿងក្តី០០៣ ប្រហែលជាមានឯកសារ៤៨៧។ បើទាក់ទងទៅនឹងរឿងក្តី០០៣ គឺថា យើងពិនិត្យមើលយើងទទួលបានការបកប្រែដោយសង្ខេបនោះ គឺ -- ហើយយើងនឹងធ្វើការបង្ហាញឯកសារផ្អែកលើករណីនេះ។ រឿងក្តី០០៤ យើងមានការបកប្រែសង្ខេបហ្នឹងមួយចំនួន ហើយយើងបានបកប្រែឯកសារពេញហ្នឹង តែ១២០០ឯកសារ។ អ៊ីចឹងអង្គភាពសាក្សី អង្គភាពជនរងគ្រោះហ្នឹង គឺថាយើងបានពិនិត្យមើលបញ្ហានេះ គឺយើងបានឮពីលោក ឌេល លីសាក់ កាលពីសប្តាហ៍មុនហ្នឹងគឺថា យើងនឹងពិនិត្យកំណត់អត្តិភាពក្នុងការពិនិត្យមើលកំណត់ហេតុសួរចម្លើយសាក្សីនោះ ពីថ្ងៃចន្ទអាទិត្យមុននោះ គឺថាយើងពិនិត្យមើលថ្ងៃទី០៣ ខែសីហា សហព្រះរាជអាជ្ញាបានទទួលឯកសារមកដល់ខ្លួន គឺថាយើងមានៗកំណត់ហេតុស្តាប់

ចម្លើយសាក្សី គឺថា៧០ទៀតដែលយើងរង់ចាំការសម្រេចពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយយើងបានស្នើ ហើយយើងបានការអនុញ្ញាត យើងនឹងដាក់បង្ហាញ។ អ៊ីចឹងហើយ គឺថាយើងមានសកម្មភាពច្រើនណាស់ក្នុងពេលដែលយើងដាក់ស្នើសុំទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយក៏មានការយល់ដឹងទទួលស្គាល់អំពីភាពចាំបាច់ដែលយើងធ្វើនេះ។ ដូច្នេះ យើងមានរយៈពេលខ្លី គឺថា យើងមានរយៈពេលតែបួន ឬប្រាំថ្ងៃទេ ក្នុងការបានការអនុញ្ញាតពីសហចៅក្រមដើម្បីនឹងអាចដាក់បញ្ជាឯកសារនោះបាន ដូចដែលមេធាវីការពារក្ដីចង់បាន។ អ៊ីចឹងគឺថាឯកសារ៦៧ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយមាន៤២ -- ១២ទាក់ទងទៅនឹងចាម, ១៤ ទាក់ទងទៅនឹងជនជាតិវៀតណាម, ៣០ ទាក់ទងទៅនឹងមន្ត្រីសាធារណរដ្ឋខ្មែរ, ប្រាំពីរ ទាក់ទងនឹងបញ្ហាជនជាតិវៀតណាម ហើយនិងយើងមានឯកសារ២៣ទៀតទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ។ មួយ ទាក់ទងទៅនឹងទំនប់១មករា ហើយមួយ ទាក់ទងទៅនឹងសហករណ៍ត្រាំកក់។ ហើយនៅពេលដែលយើងដាក់បង្ហាញឯកសារ យើងនឹងត្រូវធ្វើការដោយមធ្យ័ត ដើម្បីសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បីយើងអាចធ្វើបែបនេះបាន។

[១០:២២:២៤]

ទាក់ទងទៅនឹងឯកសារក្នុងបច្ចុប្បន្ននៃសម័យនោះ គឺថាមានឯកសារចំនួនច្រើនដែលទងទៅនឹងរឿងក្ដី០០៣ និង ០០៤ គឺវាមានលក្ខណៈចំនួនប្រហាក់ប្រហែលគ្នា។ ហើយក៏វាមានភាពពាក់ព័ន្ធនឹងសវនាការនេះដែរ ដំណាក់ការនេះដែរ។ ហើយសូមជម្រាបលោកចៅក្រមថា រឿងក្ដីនេះគឺជារឿងក្ដីធំធេង ហើយជាឯកសារច្រើន លើកលែងតែយើងចាត់តាំងបុគ្គលណាម្នាក់ឲ្យធ្វើពេញម៉ោងទៅ យើងនឹងសហការគ្នាទាំងអស់ ហើយយើងមានកិច្ចសហការ ហើយយើងក៏នឹងធ្វើការជាមួយសហមេធាវីការពារក្ដីដែរទាក់ទងទៅនឹងការដាក់បង្ហាញឯកសារនៅពេលអនាគត ថាតើយើងត្រូវធ្វើរៀងរាល់សប្ដាហ៍ម្ដង ឬពីរសប្ដាហ៍ម្ដង ដើម្បីដំណាក់កាលដំណើរទៅបានល្អ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសួរទៅសហព្រះរាជអាជ្ញា។ តាមខ្ញុំយល់ ហើយមានការកែប្រែនៅក្នុងគោលនយោបាយទាក់ទងទៅនឹងពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងត្រូវដាក់ចូលមកជាភស្ដុតាង ប៉ុន្តែមិនពាក់ព័ន្ធ -- វាមិនមានស្ថានភាពដូចគ្នាចំពោះកំណត់ហេតុស្ដាប់ចម្លើយសាក្សីទេក្នុងចំនួន៧០ ដែលថាសហព្រះរាជអាជ្ញាដាក់ទៅអង្គជំនុំជម្រះធ្វើជាភស្ដុតាង ឬក៏គ្រាន់តែដាក់ជូនជា

ឯកសារសម្រាប់ដេញដោលនោះទេ។

**លោក វីណ្ស៊៊ៀម ស្មឹត៖**

អត់ទេ មិនមែនជាករណីនោះទេ បែបនោះទេ។ សូមទោស គោលនយោបាយដែលទាក់ទងទៅនឹងការចង្អុលបង្ហាញថា តើកំណត់ហេតុស្តាប់ចម្លើយសាក្សីណាដែលយើងនឹងដាក់ជូនទាក់ទងទៅនឹងវិធាន៨៧(៤) នោះ ហើយយើងនឹងចង្អុលបង្ហាញច្បាស់នៅក្នុងសំណើររបស់យើងក្នុងការដាក់បង្ហាញជូនអង្គជំនុំជម្រះ។ មិនមែនកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ ដែលយើងនឹងបង្ហាញអង្គជំនុំជម្រះដែលយើងសុំតាមវិធាន៨៧(៤) ទាំងអស់នោះទេ។ ហើយយើងនឹងចង្អុលបង្ហាញបែបនេះនៅក្នុងសំណើរបស់យើង។ យើងនឹងប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការចង្អុលបង្ហាញបែបនោះ នៅពេលណាដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីត្រូវបានដាក់បង្ហាញ ហើយយើងនឹងអនុវត្តគោលនយោបាយរបស់យើងប្រហាក់ប្រហែលគ្នាដែរចំពោះកំណត់ហេតុស្តាប់ចម្លើយ។ ប្រហែលជាកំណត់ហេតុភាគច្រើនហ្នឹង គឺទាក់ទងទៅនឹងការដាក់បង្ហាញឯកសារតាមវិធាន៨៧(៤) នោះឯង។ នេះជាចម្លើយខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

[១០:២៥:៣៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទៅលើការដេញដោលព្រឹកនេះទាក់ទងទៅនឹងការដាក់ឯកសារ។

ជាទូទៅ ខ្ញុំយល់ឃើញថាវាមានការប៉ះពាល់ទៅដល់ការការពារសិទ្ធិរបស់លោក ខៀវ សំផន ចំពោះការដាក់ឯកសារ និងការបន្តដាក់ឯកសារជាបន្តបន្ទាប់ មិនដឹងថានឹងបញ្ចប់នៅពេលណា ដែលសូម្បីតែតំណាងសហព្រះរាជអាជ្ញាអន្តរជាតិក៏បានលើកនូវការឆ្លើយតបទៅនឹង លោកចៅក្រម ឡាវែន៍ អម្បាញ់មិញនេះ។ បញ្ហានេះខ្ញុំកត់សម្គាល់ឃើញទៅលើលក្ខណៈជាទម្រង់គឺថា ឯកសារដែលបានមកពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង០០៣ និង០០៤ ហើយបន្តយកមកដាក់នេះ គឺមិនមែនជាឯកសារពេញលេញដែលធ្វើឡើងយដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ ពីព្រោះថាមានពីរក្រុមដែលចូលគ្នានៅក្នុងក្រុមសហចៅក្រមស៊ើបអង្កេត ដែលត្រូវរៀបចំធ្វើឯកសារស៊ើបអង្កេតទាំងអស់នោះ។ នេះជាបញ្ហាបច្ចេកទេសដែលយើងឃើញមានទំនាស់ចម្រូងចម្រាសនៅក្នុងសំណុំរឿង

០០៣ និងសំណុំរឿង០០៤នេះ។ ហើយដូចគ្នានេះផងដែរ ការដាក់បង្ហាញឯកសារនេះសម្រាប់ការិយាល័យសហព្រះរាជអាជ្ញា គឺយើងឃើញថាមានបញ្ហាចម្រូងចម្រាសនេះដែរ ដោយសារការលើកឡើងនេះគឺជាការលើកឡើងរបស់ ការបង្ហាញឡើងរបស់សហចៅក្រម -- សូមទោស សហព្រះរាជអាជ្ញាអន្តរជាតិ មិនមែនជាការបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញាទាំងអស់ទេ ទាំងមូលទេ បាទ។

[១០:២៧:២៨]

ដូច្នេះ វាមានចំណុចខ្វែងគ្នា ដែលយើងមើលឃើញពីការគាំទ្រទៅលើការស៊ើបអង្កេតក្ដីនៅក្នុងសំណុំរឿង០០៣ និង ០០៤ ដែលឯកសារទាំងនោះត្រូវលើកយកមកដាក់នៅក្នុងសំណុំរឿង០០២ នេះ។ ហើយទាក់ទងនឹងបញ្ហានេះ ខ្ញុំបានស្ដាប់ឮសហព្រះរាជអាជ្ញាអន្តរជាតិលើកអំពីការដាក់ឯកសារដែលថាទោះបីជាឯកសារដាក់បន្ទុក ឬក៏ឯកសារដោះបន្ទុកក៏ដោយ លោកនឹងបង្ហាញទាំងអស់បាទ។ នេះជាចំណុចល្អ ជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាដែលត្រូវធ្វើ ក៏ប៉ុន្តែជាក់ស្ដែងអ្វីដែលយើងឃើញនៅក្នុងឯកសារដែលបានបង្ហាញកន្លងមកនេះ គឺមានតែឯកសារដាក់បន្ទុកតែប៉ុណ្ណោះ។ ដូច្នេះ វាបង្ហាញនូវចំណុចអវិជ្ជមានជាច្រើនសម្រាប់ការការពារក្ដី សម្រាប់សិទ្ធិលោក ខៀវ សំផន ក្នុងការប្រើប្រាស់នៅមធ្យោបាយការពារសមស្របតាមផ្លូវតុលាការនេះ។ អ៊ីចឹងជាសំណើរបស់ខ្ញុំ ខ្ញុំយល់ឃើញថា តុលាការគួរមានការកំណត់ពេលវេលាជាក់លាក់ក្នុងការដាក់ឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលយកចេញពីសំណុំរឿង០០៣ និង ០០៤ មកប្រើប្រាស់នៅក្នុងសំណុំរឿង០០២។

ការកំណត់ពេលវេលាជាក់លាក់នេះ វាអាចកាត់បន្ថយការប៉ះពាល់ដល់សិទ្ធិការពារក្ដីរបស់លោក ខៀវ សំផន ហើយក៏វាអាចមិនបង្កឲ្យមានភាពស្មុគស្មាញទៅដល់នីតិវិធីនៃការដាក់សំណុំរឿង ដាក់ឯកសារចូលក្នុងសំណុំរឿងបន្ថែមជាបន្តបន្ទាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិនោះដែរ។ ក៏ប៉ុន្តែ ការដាក់ឯកសារបន្ថែមនេះ វាមិនមែនជាការកម្រិតដល់សិទ្ធិដាក់ឯកសាររបស់ខាងភាគីជនជាប់ចោទនោះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ សវនាការនឹងលើកបន្តធ្វើនៅពេលរសៀលនេះចាប់ផ្ដើមពីម៉ោងមួយ សាមសិបនាទីទៅ។ នៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-881។ ដូច្នេះ សូមភាគីនឹងសាធារណជនជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកវិញ ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការជាបន្តទៀត។ ដូចអង្គជំនុំជម្រះបានជូនដំណឹងទៅភាគីរួចហើយ នៅរសៀលនេះ យើងនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-881 ទាក់ទងនឹងអង្គហេតុទំនប់ត្រពាំងថ្ម។ ហើយបន្ទាប់ពីបញ្ចប់សាក្សីនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-889។ ចំណែកឯសាក្សីបន្តទៀត អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីនៅចុងម៉ោងនៅថ្ងៃសវនាការនេះ។

បង្គាប់ទៅមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-881 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន សម្រាប់ភាគី គឺអំមិញ អម្បាញ់មិញនេះ យើងស្តាប់ឮថា បន្ទាប់មកយើងនឹងស្តាប់សាក្សី 2-TCW-289 ក៏ប៉ុន្តែតាមពិតទៅសាក្សីបន្ទាប់នោះគឺ 2-TCW-889 ទេ មិនមែន 289 ដូចការបកប្រែទេ។

[១៣:៣២:២៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអ្វី?

**លោក កាន ផុល៖**

**ឆ៖** ឈ្មោះ កាន ផុល។

**ស៖** តើលោកកើតនៅឆ្នាំណា ខែណា?

ឈប់ៗសិនលោកកុំអាលទាន់ឆ្លើយ ចាំមីក្រូហ្វូន លោកបង្ហាញភ្លើងពណ៌ក្រហមចាំលោកឆ្លើយបាទ។

**ឆ៖** កើតនៅឆ្នាំ ១៩៥៨។

**ស៖** តើលោកប្រកបមុខរបរអ្វីដែរ សព្វថ្ងៃនេះ?

សូមលោកចាំមីក្រូហ្វូនប្រតិបត្តិការណ៍សិន ចេញភ្លើងពណ៌ក្រហមចាំលោកឆ្លើយបាទ។

**ឆ៖** មុខរបរខ្ញុំធ្វើស្រែ។

**ស៖** តើឪពុកលោក ម្ដាយលោកឈ្មោះអ្វីដែរ?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ណាក សំអាន ម្ដាយឈ្មោះ ផុន ប៉ន។

**ស៖** លោកមានប្រពន្ធឈ្មោះអ្វី ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ តាំង សាឡុំ មានកូន បួននាក់។

**ស៖** អរគុណលោកសាក្សី។ តាមសមត្ថភាពនិងលទ្ធភាព ដែលលោកអាចដឹង តើលោកមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ ដែរទេ?

**ឆ៖** គ្មានទេ។

**ស៖** តើលោកបានស្បថហើយឬនៅមុនចូលជំនុំជម្រះ -- អង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ ខ្ញុំបានស្បថរួចហើយ។

[១៣:៣៥:១១]

**ស៖** អរគុណលោក។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោក។ ក្នុងឋានៈលោកជាសាក្សីនៅចំពោះអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក កាល ថុល ក្នុងឋានៈលោកជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនលោក។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយរបស់ភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរសំណួរលោក។ លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។

ដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគីសួរចំពោះលោក។ តើលោកយល់ឬទេ?

**ឆ៖** បាទ យល់ហើយ។

**ស៖** លោកសាក្សី តើលោកដែលផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងពេលកន្លងមក? ហើយប្រសិនជាបានធ្វើ តើធ្វើប៉ុន្មានដង? ធ្វើនៅពេលណា? នៅកន្លែងណាដែរ?

**ឆ៖** បាទ បានធ្វើមួយដង នៅភូមិប៉ោយស្នួល។

**ស៖** អរគុណ។ ហើយនិងមុនពេល -- នៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ បានអានរួចហើយ។

[១៣:៣៧:៥៩]

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរឬទេថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកាការចងចាំហ្នឹង វាពិតជាត្រឹមត្រូវ វាស៊ីចង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទបញ្ញាតិ៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី កាន ថុល នេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញា រួមទាំងៗសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលពេញមួយរសៀលនេះ ក្នុងការសួរដេញដោលទៅសាក្សីរូបនេះ។

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម អស់លោកលោកស្រីដែលមានវត្តមាននៅក្នុងអង្គសវនាការនារសៀលនេះ។

[១៣:៣៩:១៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះ ខ្ញុំមានសំណួរទៅលើប្រធានបទចំនួនបី ដើម្បីសួរទៅឲ្យលោកសាក្សីជួយបំភ្លឺដល់អង្គសវនាការ។ សំណួរ -- ប្រធានបទទី១ គឺពាក់ព័ន្ធជាមួយនឹងប្រវត្តិលោកមួយចំនួនមុន និងក្រោយឆ្នាំ៧៥។ ប្រធានបទទី២ គឺពាក់ព័ន្ធជាមួយនឹងបញ្ហាទូទៅមួយចំនួនទៅនឹងការងារនៅអាងត្រពាំងថ្ម។ ហើយខ្ញុំនឹងចូលទៅសួរសំណួរលម្អិតមួយចំនួនទៀត ពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌការងារនៅក្នុងការសាងសង់ទំនប់អាងត្រពាំងថ្ម។ ហើយបន្ទាប់មកទៀត សហការីអន្តរជាតិខ្ញុំនឹងមានសំណួរទៅលើប្រធានបទជាបន្តបន្ទាប់ទៀត។ សំណួរដំបូងរបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់បន្តិចថា តើលោកកើតនៅទីណា? ហើយនៅឆ្នាំណាដែរ?

**លោក កាន ថុល៖**

**ឆ៖** បាទ ខ្ញុំកើតនៅភូមិត្រពាំងថ្មកណ្ដាល។ កើតនៅឆ្នាំ១៩៥៨។

**ស៖** អរគុណលោកសាក្សី។ តើលោកអាចប្រាប់បានទេ ថាតើលោកចូលរួមជាមួយនឹងចលនាតស៊ូខ្មែរក្រហមហ្នឹងនៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំអត់មានបានចូលទេ។

[១៣:៤១:១៦]

**ស៖** តើនៅចន្លោះ -- តើក្រោយឆ្នាំ៧៥បន្តិចនេះ តើលោកធ្វើអី នៅកន្លែងណាដែរ?

**ឆ៖** បាទ ក្រោយឆ្នាំ៧៥ ខ្ញុំបានធ្វើជាកងចល័ត។

**ស៖** កងចល័តនៅណាដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ចល័តតាមស្រុក។

**ស៖** ស្រុកៗណាដែរលោក?

**ឆ៖** បាទ មានចល័តរហូតមកដល់ស្រុកសិរិសោភ័ណ។

**ស៖** លោកអាចបញ្ជាក់បានទេថា លោកធ្វើការនៅក្នុងកងចល័តហ្នឹងឈ្មោះអី?

**ឆ៖** សូមសួរម្តងទៀត។

**ស៖** លោកបានប្រាប់ថា លោកធ្វើការនៅកងចល័តស្រុក។ ខ្ញុំចង់បញ្ជាក់ថា កងចល័តស្រុកហ្នឹងស្រុកមួយណា?

**ឆ៖** បាទ គឺស្រុកភ្នំស្រុក។

**ស៖** តើលោកអាចប្រាប់បានទេ លោកធ្វើអីខ្លះនៅក្នុងកងចល័តនោះ?

**ឆ៖** ដំបូងនៅកងចល័ត ខ្ញុំមិនទាន់បានធ្វើអ្វីទេ ដើរតែចល័តតែប៉ុណ្ណោះ។

**ស៖** តើលោកមានតួនាទីអីនៅក្នុងកងចល័តហ្នឹងដែរ?

**ឆ៖** ក្រោយមកទៀត ខ្ញុំមានតួនាទីជាអនុប្រធានកងតូច។

[១៣:៤៣:៥០]

**ស៖** ខ្ញុំ សំណួរខ្ញុំអត់ទាន់ដល់ទៅការងារនៅទំនប់ត្រពាំងថ្មទេ។ ខ្ញុំចង់សួរថាការងារនៅក្នុងកងចល័តនៅស្រុកភ្នំស្រុកនេះ។ តើលោកអាចបញ្ជាក់ទេ នៅពេលដែលនៅកងចល័តភ្នំស្រុកហ្នឹង លោកមានតួនាទីអ្វីដែរ?

**ឆ៖** បាទ អង្កាល់នៅកាលចល័តស្រុកភ្នំស្រុកនោះ អត់មានតួនាទីអ្វីទេ។

**ស៖** សូមថយមកបន្តិច ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្តិច ថាតើលោកជាប្រជាជនមូលដ្ឋាន ឬក៏ជាប្រជាជនថ្មីដែរ?

**ឆ៖** បាទ ខ្ញុំជាប្រជាជនមូលដ្ឋាន។

**ស៖** អរគុណលោក។ សូមបែរត្រឡប់មកនេះវិញ កងចល័តរបស់លោកវិញ។ នៅក្នុងកង

ចល័តភ្នំស្រុកហ្នឹង តើមានសមាជិកប៉ុន្មាននាក់ដែរ លោកអាចប្រាប់បានទេ?

**ឆ៖** បាទ ដំបូងហ្នឹងមានប្រហែលជា ១០០នាក់។

**ស៖** លោកមានប្រសាសន៍ថា ដំបូងមាន ១០០នាក់ ចុះបន្ទាប់មកមានប៉ុន្មានដែរ?

**ឆ៖** ក្រោយមកនៅតែ ៧០នាក់។

**ស៖** លោកថាក្រោយមកនៅ ៧០នាក់ តើ ៣០នាក់ទៅណា?

**ឆ៖** បាទ ខ្លះរត់មកមូលដ្ឋានវិញ ខ្លះក៏ឈឺដេកពេទ្យ។

**ស៖** មូលហេតុអីបានជាគេរត់ចេញពីកងចល័តហ្នឹង លោកអាចប្រាប់បានទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជាភាសាបារាំងប្រហែលជាមានបញ្ហាបកប្រែ ព្រោះថាតួលេខនោះ គ្មានន័យទេ អ៊ីចឹងសូមឱ្យសហព្រះរាជអាជ្ញាជាតិជួយសួរវិញម្តងទៀត ព្រោះថាយើងស្តាប់ឮបកប្រែជាភាសាបារាំងនេះគឺថា តួលេខ ចេញអម្បាញ់មិញ ដូចជា ៣០អ៊ីចឹង ខ្ញុំមើលទៅដូចជាអត់មានខ្លឹមសារ។ សូមឱ្យលោកសហព្រះរាជអាជ្ញាជួយបំភ្លឺឡើងវិញម្តងទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក សេង លាង៖**

ខ្ញុំក៏ស្តាប់ឮការបកប្រែជាភាសាអង់គ្លេសចំនួន៣០ដែរ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ម្តងទៀត។

**សួរដោយលោក សេង លាង៖**

**ស៖** លោកសាក្សី តើលោកអាចប្រាប់បានទេ លោកបានមានប្រសាសន៍ថា សមាជិកកងរបស់លោកហ្នឹងមានគ្នា ១០០នាក់ ហើយក្រោយមក តើនៅសល់ប៉ុន្មាននាក់ដែរ?

**លោក កាន ថុល៖**

**ឆ៖** បាទ ក្រោយមកនៅសល់ ៧០នាក់។

**ស៖** លោកប្រធាន ខ្ញុំសូមទៅកាន់សំណួរខ្ញុំវិញ។ ដែលខ្ញុំចង់សួរលោកថា តើមូលហេតុអីបានជាមនុស្ស -- ហេតុអ្វីបានជានៅសល់តែចំនួន ៧០នាក់ហ្នឹង ៣០នាក់ទៀតទៅណា?

[១៣:៤៨:២៣]

**ឆ៖** បាទ ៣០នាក់ហ្នឹង ខ្លះឈឺចូលដេកពេទ្យ ខ្លះក៏រត់ត្រឡប់មកមូលដ្ឋានភូមិ ឃុំ វិញ។

**ស៖** លោកអាចប្រាប់បានទេ តើហេតុអ្វីបានជាមានមនុស្សរត់ចេញពីកងចល័តនោះ?

**ឆ៖** បាទ ដោយសារគេទៅនៅឆ្ងាយពីភូមិកំណើត ហើយនៅដេកហាលភ្លៀង។

**ស៖** ចុះចំណែកលោកវិញ តើការដែលទៅធ្វើការនៅកងចល័តហ្នឹងជាការជ្រើសរើសរបស់លោក ឬក៏គេតម្រូវឲ្យលោកទៅធ្វើ?

**ឆ៖** បាទ គឺគេតម្រូវឲ្យខ្ញុំធ្វើ។

**ស៖** តើលោក លោកថាគេតម្រូវឲ្យលោកធ្វើ។ ហេតុអ្វីក៏លោកមិនបដិសេធនូវនឹងការតម្រូវរបស់គេហ្នឹងទៅ?

**ឆ៖** បាទ មិនហ៊ានទេៗ។

**ស៖** ហេតុអីបានជាលោកមិនហ៊ាន?

**ឆ៖** បាទ ព្រោះខ្លាច។

**ស៖** ខ្លាចអីលោក? អាចបញ្ជាក់ឲ្យច្បាស់បន្តិចបានទេលោក?

**ឆ៖** បាទ ខ្លាចច្បាប់របស់គេ ខ្លាចគេធ្វើម៉េចៗ។

**ស៖** លោកអាចបញ្ជាក់បានទេ ធ្វើម៉េចៗ ហ្នឹង? ខ្លាចច្បាប់ ហើយធ្វើម៉េចៗហ្នឹង? បញ្ជាក់ឲ្យច្បាស់មកលោក យ៉ាងម៉េចមានន័យថា?

**ប្រធានអង្គជំនុំ៖**

សូមលោកឆ្លើយម្តងទៀត ចាំក្បាលមីក្រូប្រតិបត្តិការចេញភ្លើងព័ណ៌ក្រហម សឹមលោកឆ្លើយបាទ។

**លោក កាន ថុល៖**

**ឆ៖** គឺខ្ញុំខ្លាចគេយកទៅវ៉ៃចោល។

**សួរដោយលោក សេង លាង៖**

**ស៖** អរគុណលោក។ ឥឡូវខ្ញុំ បែរមកការងារមួយចំនួននៅអាងត្រពាំងថ្មវិញ។ តើលោកធ្លាប់ចូលរួមសកម្មភាពសាងសង់ទំនប់អាងត្រពាំងថ្មដែរទេលោក?

**ឆ៖** បាទ គឺខ្ញុំបានចូលរួមផ្ទាល់។

**ស៖** តើលោកអាចប្រាប់បានទេថា ការដ្ឋានត្រពាំងថ្មហ្នឹងស្ថិតនៅកន្លែងណា? ស្ថិតនៅក្នុងភូមិភាគណា និងតំបន់ណាដែរ?

**ឆ៖** អាងត្រពាំងថ្មស្ថិតនៅក្នុងភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ក្នុងតំបន់៥ ភូមិភាគពាយ័ព្យ។

**ស៖** អរគុណលោក។ តើលោកដឹងទេថា សកម្មភាពសាងសង់ទំនប់អាងត្រពាំងថ្មហ្នឹង ចាប់ផ្ដើមពីពេលណាដែរ?

**ឆ៖** បាទ គឺចាប់ផ្ដើមពីថ្ងៃទី១៤ ខែ០២ ឆ្នាំ១៩៧៧។

**ស៖** អរគុណលោក។ ចុះចំណែកលោកវិញ តើលោកចាប់ផ្ដើមចូលធ្វើការនៅក្នុងការដ្ឋានហ្នឹងនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំគឺចាប់ផ្ដើមចូលពីថ្ងៃទី១៤ ហ្នឹងហើយ។

[១៣:៥៣:២២]

**ស៖** តើនៅពេល លោកអាចប្រាប់បានទេ នៅពេលដែលគេបើកការដ្ឋានហ្នឹង គេមានប្រារព្ធពិធីអីដែរទេ?

**ឆ៖** បាទ បើការដ្ឋានហ្នឹង គឺគេមានធ្វើសន្និបាត។

**ស៖** តើលោកមានដឹងថា មានស្គាល់អ្នកផ្សេងទៀតដែលលោកស្គាល់ដែលចូលរួមជាមួយនឹងលោកដែរឬទេ?

**ឆ៖** បាទ មានស្គាល់។

**ស៖** លោកស្គាល់ឈ្មោះគាត់ដែរឬទេលោក?

**ឆ៖** បាទៗ បាទស្គាល់ៗឈ្មោះ សឿ សាំ។

**ស៖** តើលោកដឹងថាអ្នកណាគេជាអធិបតី ហើយនៅក្នុងពិធីនោះដែរទេ?

**ឆ៖** បាទ ខ្ញុំដឹង។

**ស៖** អ្នកណាគេលោក អាចជួយបញ្ជាក់ផង? លោកជួបបញ្ជាក់ម្ដងទៀត គាត់ឈ្មោះអីអ្នក--

**ឆ៖** បាទ អ្នកបើកសន្និបាតហ្នឹងគឺឈ្មោះ តាញ៉ឹម។

**ស៖** តើពេលនោះ តាញ៉ឹម គាត់បាននិយាយអីខ្លះ?

**ឆ៖** គាត់បាននិយាយថា “កងកម្លាំងដែលចូលមកលើកអាងត្រពាំងថ្មនេះមានចំនួន ១៥.០០០

នាក់”។

**ស៖** លោកអាចប្រាប់បានទេ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចថា តើនៅពេលដែលលោកមកធ្វើការនៅក្នុងអាងត្រពាំងថ្មនេះ គឺលោកធ្វើការនៅក្នុងសហករណ៍ដដែល ឬក៏កងចល័តដដែល ឬក៏ៗនៅក្នុងកងចល័តមួយផ្សេងខុសពីហ្នឹង?

[១៣:៥៦:១៥]

**ឆ៖** បាទ ដំបូងខ្ញុំចល័ត គេហៅថា ចល័តតាមសហករណ៍ ចេញពីសហករណ៍។

**ស៖** ពីមុនលោកប្រាប់ថា លោកធ្លាប់ធ្វើការនៅកងចល័តនៅស្រុកភ្នំស្រុក ប៉ុន្តែនៅពេលដែលលោកមកជីកអាងត្រពាំងថ្មនេះ តើលោកធ្វើនៅក្នុងកងចល័តហ្នឹងដដែល ឬក៏កងផ្សេង?

**ឆ៖** បាទ ក្រោយពីចល័តក្នុងស្រុកហើយ ខ្ញុំបានវិលត្រឡប់មកសហករណ៍វិញ។

**ស៖** អ៊ីចឹងមានន័យថា លោកឈប់ធ្វើការនៅក្នុងកងចល័តភ្នំស្រុកហ្នឹងហើយ លោកមកធ្វើការនៅសហករណ៍ហើយពេលដែលលោកមកធ្វើការនៅអាងត្រពាំងថ្ម ឬយ៉ាងណា?

**ឆ៖** បាទ ពេលនោះគេឲ្យកម្លាំងចល័តទាំងអស់របស់ខ្ញុំនេះវិលចូលមកសហករណ៍វិញ ហើយក៏ទៅលើកអាងទឹកត្រពាំងថ្មទាំងអស់គ្នា។

**ស៖** លោកអាចប្រាប់បានទេថា តើនៅពេលណាដែលកិច្ចការសាងសង់អាងត្រពាំងថ្មនេះត្រូវបានបញ្ចប់?

**ឆ៖** បាទ អាងត្រពាំងថ្មនេះបញ្ចប់នៅឆ្នាំ៧៧ ដដែល។

**ស៖** ចុះចំណែកលោកវិញ តើលោកឈប់ធ្វើការនៅការដ្ឋានអាងត្រពាំងថ្ម និងនៅពេលណា? មុន ឬក្រោយពេលការបញ្ចប់ហ្នឹង?

**ឆ៖** បាទ ក្រោយពីធ្វើអាងត្រពាំងថ្មរួច គេឲ្យជីកប្រឡាយចេញពីអាងត្រពាំងថ្មមកដល់គោករំចេក។

**ស៖** តើលោកអាចប្រាប់បានទេថា តើនៅពេលដែលអាងត្រពាំងថ្មហ្នឹងត្រូវបានបញ្ចប់នោះ តើគេមានរៀបចំពិធីអីដែរឬទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** លោកអាចប្រាប់បានទេថា តើទំនប់អាងត្រពាំងថ្មនេះវាមានទំហំប៉ុន្មាន? ប្រវែងប៉ុន្មានដែរលោក?

[១៣:៥៩:៥២]

**ឆ៖** អាងត្រពាំងថ្មនេះមានទំហំបាតវាប្រហែលជា១៨ ទៅ ២០ម៉ែត្រ ខាងលើ ១០ម៉ែត្រ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ប្រជាជនដែលចូលរួមក្នុងការសាងសង់អាងត្រពាំងថ្មនេះ គេយកមកពីតំបន់ណាខ្លះ?

**ឆ៖** អ្នកដែលចូលរោងលើកអាងត្រពាំងថ្មទាំងអស់ គឺគេយកមកពីតំបន់៥ ក្នុងនោះមានបួនស្រុក គឺស្រុកព្រះនេត្រព្រះ ស្រុកសិរីសោភ័ណ ស្រុកថ្មពួក ហើយនិងស្រុកភ្នំស្រុក។

**ស៖** លោកអាចលម្អិតបន្តិចមើលអំពីសមាសភាព តើមានបុរស ស្ត្រី ឬក៏មានកូនក្មេងអីចូលរួមក្នុងការងារហ្នឹងដែរទេ?

**ឆ៖** បាទ ក្នុងនោះមានវ័យកណ្ដាល ហើយនិងយុវជន នារី ព្រមទាំងកុមារជំទង់។

**ស៖** យុវជនជំទង់ដែលមានប្រសាសន៍ហ្នឹង លោកអាចបញ្ជាក់ទេ ពួកគេមានអាយុប្រហែលជាពីប៉ុន្មានដល់ប៉ុន្មានដែរ?

**ឆ៖** បាទ កុមារហ្នឹងមានអាយុពីក្រោម ១៨ឆ្នាំ ដល់ ១៥ឆ្នាំ។

**ស៖** តើចំនួនកុមារវ័យជំទង់នេះច្រើនដែរឬទេ បើប្រៀបធៀបជាមួយនឹងចំនួនសរុប?

**ឆ៖** បាទ មិនសូវច្រើនទេ បាទ។

**ស៖** ឥឡូវខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធជាមួយនឹលក្ខខណ្ឌការងារ។ សូមលោកជួយបញ្ជាក់មើលថា នៅពេលដែលលោកបំពេញការងារនៅអាងត្រពាំងថ្មហ្នឹងគឺលោកមានតួនាទីអីដែរ?

**ឆ៖** បាទ កាលនោះ ខ្ញុំមានតួនាទីជាអនុប្រធានកងតូច។

**ស៖** សូមជួយលម្អិតមើល ថាតើមានមនុស្សប៉ុន្មាននាក់នៅក្រោមការគ្រប់គ្រងរបស់លោក?

**ឆ៖** បាទ មាន ៣០នាក់។

**ស៖** លោកជួយប្រាប់មើលថា លោកបែងចែកការងារហ្នឹងរបៀបណាដែរ?

**ឆ៖** បាទ បែងចែកការងារហ្នឹងគឺ ព្រឹកឡើងនាំគ្នាចេញទៅធ្វើការ។

**ស៖** ចង់ឲ្យលោកជួយបញ្ជាក់បន្តិចថា ក្នុងចំណោម ៣០នាក់ហ្នឹងលោកបែងចែកជាក្រុម ឬក៏អីយ៉ាងម៉េចដែរ ក្នុងការឲ្យធ្វើការហ្នឹង?

**ឆ៖** បាទ ក្នុង៣០នាក់ហ្នឹង មានបីក្រុម។

**ស៖** តើលោកអាចបញ្ជាក់បានទេថាកូនក្រុមរបស់លោកហ្នឹង គឺត្រូវបំពេញការងារអីខ្លះ?

**ឆ៖** បាទ កូនក្រុមរបស់ខ្ញុំនោះ មានម្នាក់ជាចុងភៅ ម្នាក់ទៀតដើរបាចត្រី។

**ស៖** ចុះអ្នកផ្សេងទៀតធ្វើអ្វីដែរ?

**ឆ៖** បាទ ក្រៅពីនោះទៅលើកដីទាំងអស់គ្នា។

**ស៖** ចុះក្នុងឋានៈលោកជាអនុប្រធានកងហ្នឹង តើលោករៀបរាប់បន្តិចមើលអំពីតួនាទី និងភារកិច្ចរបស់លោកក្នុងការគ្រប់គ្រងកូនក្រុមរបស់លោក?

**ឆ៖** បាទ សូមៗម្តងទៀត។

**ស៖** ខ្ញុំចង់ឲ្យថា លោកបានមានប្រសាសន៍ថាលោកជាអនុប្រធានកង។ អនុប្រធានកងហ្នឹងក្នុងឋានៈលោកជាអនុប្រធានកងហ្នឹង តើលោក ចូររៀបរាប់អំពីតួនាទី និងភារកិច្ចរបស់លោកក្នុងការគ្រប់គ្រងកូនក្រុមរបស់លោកហ្នឹង តើលោកធ្វើអ្វីខ្លះ?

**ឆ៖** បាទ ក្នុងនាមជាអនុប្រធានកងគឺ អត់មានអ្វីទេ គឺព្រឹកៗឡើង គឺដឹកនាំកូនក្រុមហ្នឹងទៅលើកដីទាំងអស់គ្នា ហើយនិងមើលអ្នកណាឈឺប៉ុន្មាននាក់។

**ស៖** តើលោកមានបានចូលរួមក្នុងការរែកដីជាមួយកូនក្រុមរបស់លោកដែរឬទេ?

**ឆ៖** បាទ បានចូលរួម។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ក្នុងក្រុមរបស់លោក ៣០នាក់ហ្នឹង តើពួកគេជ្រើសរើសដោយខ្លួនឯងទៅធ្វើការនៅអាងត្រពាំងថ្មហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គឺថ្នាក់លើគេចាត់តាំងឲ្យមក។

**ស៖** តើពួកគេមានសិទ្ធិក្នុងការតវ៉ា ឬបដិសេធមិនទៅធ្វើដែរឬទេ?

**ឆ៖** បាទ អត់មានទេ។

[១៤:០៨:០៥]

**ស៖** ក្នុងការលើកដីនៅទំនប់អាងត្រពាំងថ្មហ្នឹង តើលោកបានផ្តល់សម្ភារៈអ្វីខ្លះដល់កូនក្រុមរបស់លោកក្នុងការលើកដីហ្នឹង?

**ឆ៖** បាទ សម្ភារៈហ្នឹងគឺមាន មុងៗមួយ ហើយនិងចប បង្គី។

**ស៖** តើមានការប្រើប្រាស់គ្រឿងយន្តដែរឬទេ?

**ឆ៖** បាទ នៅពេលដំបូងមាន បាទ មានគ្រឿងយន្តចំនួនប្រាំគ្រឿង។

**ស៖** គ្រឿងយន្តនោះគេប្រើសម្រាប់ធ្វើអ្វីដែរ?

ឆ៖ គ្រឿងយន្តនោះគឺគេប្រើសម្រាប់ឈូសព្រៃដែលនៅតាមបណ្ដោយដែលត្រូវលើទំនប់នោះ។
ស៖ អ៊ីចឹងមានន័យថា គ្រឿងយន្តហ្នឹង មិនមែនសម្រាប់ក្រុមរបស់លោកប្រើទេ។ មែនទេ?
ឆ៖ បាទ អត់មានទេ។
ស៖ ក្នុងការលើកដីនៅទំនប់អាងត្រពាំងថ្មហ្នឹង តើគេមានដាក់ផែនការកំណត់ថា ក្នុងមួយនាក់រែកឲ្យបានប៉ុន្មានទេ ក្នុងមួយថ្ងៃ?
ឆ៖ បាទ ក្នុងមួយថ្ងៃ ៣ម៉ែត្រគូប។
ស៖ ក្នុងការកំណត់៣ម៉ែត្រគូបដូចលោកមានប្រសាសន៍ហ្នឹង តើលោកជាអ្នកកំណត់ ឬក៏ថ្នាក់លើជាអ្នកកំណត់?
ឆ៖ បាទ គឺថ្នាក់លើជាអ្នកកំណត់។
ស៖ តើគេមានប្រជុំពិភាក្សាជាមួយប្រជាជនទេថា សួរយោបល់ប្រជាជនថា តើ៣ម៉ែត្រគូបហ្នឹង ប្រជាជនអាចធ្វើទៅរួចដែរឬទេ?
ឆ៖ អត់ទេ។
ស៖ តាមការសង្កេតរបស់លោក នៅក្នុងក្រុមរបស់លោកហ្នឹង តើកូនក្រុមរបស់លោកប៉ុន្មានភាគរយដែលអាចធ្វើបាន៣ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹង?
ឆ៖ បាទ ដំបូងដែលដីទើបកាប់ ទំនប់នៅទាប អាចធ្វើបាន៨០ភាគរយ។
ស៖ ពេលក្រោយមកទៀតហ្នឹង តើនៅសល់ប៉ុន្មានភាគរយនៅពេលដែលទំនប់កាន់តែខ្ពស់ ហើយដីជីកកាន់តែជ្រៅហ្នឹង តើៗមានប៉ុន្មានភាគរយ អាចឆ្លើយ អាចធ្វើបានតាមផែនការ?
[១៤:១២:១៣]
ឆ៖ ធ្វើបានតាមផែនការតែ២០ ទៅ៣០ភាគរយប៉ុណ្ណោះ។
ស៖ តើថ្នាក់លើ គាត់មានផែនការយ៉ាងណាដែរនៅពេលដែលក្ដាប់បានថា ២០ តែ២០ ទៅ៣០ភាគរយ ធ្វើបានតាមផែនការអ៊ីចឹង?
ឆ៖ បាទ គឺថ្នាក់លើ គេហៅមេកងទៅប្ដេជ្ញាចិត្តធ្វើឲ្យបាន។
ស៖ លោកដឹងរឿងនេះ តាមរបៀបណាដែរ?
ឆ៖ បាទ ពេលគេហៅទៅប្រជុំ។
ស៖ នៅពេលហ្នឹង មេកងរបស់លោក គេបាននិយាយថាយ៉ាងម៉េចដែរ លោកអាចចាំទេ?

**ឆ៖** បាទ មេកងនេះពុំដែលប៊ានប្រកែកទេ ចេះតែថាបានៗ។

**ស៖** អ៊ីចឹងនៅពេលដែលគាត់ត្រឡប់ពីប្រជុំវិញ តើគាត់ចាត់ចែងយ៉ាងណាជាមួយនឹងកូនក្រុមរបស់គាត់ហ្នឹង ដើម្បីឆ្លើយតបតាមផែនការដែលគេតម្រូវ លោកដឹងដែរ?

**ឆ៖** បាទ ពេលគាត់ត្រឡប់មកពីប្រជុំវិញ គាត់ហៅកូនក្រុមទាំងអស់ប្រជុំ ហើយឲ្យប្ដេជ្ញាចិត្តទាំងអស់គ្នា។

**ស៖** ក្រោយពីប្ដេជ្ញាចិត្ត តើនៅមានអ្នកដែលមិនអាចធ្វើបានតាមផែនការហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ នៅតែមាន។

**ស៖** តើអ្នកណាគេជាអ្នកត្រួតមើល ថាតើផែនការដែលគេដាក់ឲ្យហ្នឹងសម្រេចបានឬអត់?

**ឆ៖** គឺប្រធានវរៈ។

**ស៖** លោកនៅចាំឈ្មោះគាត់ដែរឬទេ?

**ឆ៖** បាទ ចាំបាន។

[១៤:១៥:៣៥]

**ស៖** តើមានអ្វីកើតឡើងនៅពេលដែលគេពិនិត្យទៅឃើញថា ប្ដេជ្ញាហើយនៅតែធ្វើមិនបានតាមផែនការហ្នឹង?

**ឆ៖** បាទ ពេលដែលធ្វើមិនបានតាមផែនការ គេមិនដែលយកទោសទេ ប៉ុន្តែគេគ្រាន់តែទិតៀនហើយនិងកសាងម្ដងហើយម្ដងទៀត។

**ស៖** លោកអាចលម្អិតបន្តិចបានទេ ថាទិតៀន និងកសាងហ្នឹងគេម៉េចដែរ?

**ឆ៖** បាទ ការទិតៀនកសាងហ្នឹង គឺគេថាយើងធ្វើហ្នឹងមិនបានហ្នឹង គឺមកអំពីយើងនៅស្ទើកស្រពន់ នៅតែមានការខ្ជិល ធ្វើមិនអស់សមត្ថភាព។

**ស៖** នៅពេលដែលគេបន្ទោសថា ជាអ្នកខ្ជិលច្រអូសហ្នឹង លោកមានដឹងថាតើគេមានវិធានការអីដែលបន្ទាប់ដែរទៀតដែរឬអត់?

**ឆ៖** បាទ មិនដែលឃើញមានទេ។

**ស៖** អរគុណលោកសាក្សី ខ្ញុំនៅមានប្រហែលជាពីរបីសំណួរទៀតទេ។ ឥឡូវខ្ញុំសួរវិញនៅសំណួរមួយទៀត ពាក់ព័ន្ធនឹងថាតើលោកបញ្ជាក់បានទេ ថាម៉ោងពេលធ្វើការនៅការដ្ឋានហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ ពេលព្រឹកទៅដល់ការដ្ឋានម៉ោងប្រាំពីរព្រឹក ឡើងហូបបាយម៉ោងដប់មួយ ចុះទៅវិញម៉ោងមួយរសៀល ល្ងាចម៉ោងប្រាំ គឺឡើងមកវិញ។

**ស៖** ចុះចំណែកពេលយប់ មានធ្វើដែរឬទេលោក?

**ឆ៖** បាទ នៅពេលយប់មានធ្វើខ្លះៗដែរ។

**ស៖** លោកអាចបញ្ជាក់បានទេ ម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** ពីម៉ោងប្រាំពីរល្ងាច ដល់ម៉ោងដប់យប់។

**ស៖** អរគុណលោក។ ចុះមានពេលណាខ្លះដែលការងារត្រូវធ្វើប្រញាប់ ហើយតម្រូវឲ្យធ្វើលើសពីម៉ោងដប់យប់ហ្នឹងដែរឬទេ?

**ឆ៖** បាទ មាន។

**ស៖** លោកអាចបញ្ជាក់បានទេ ថាគេធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានខ្លះ អាចបញ្ជាក់ជូនអង្គសវនាការ?

**ឆ៖** ពេលសម្រុកផ្តាច់ព្រ័ត្រ គេឲ្យលើកមួយយប់វាល់ព្រឹក ផ្លាស់គ្នាប្តូនដង។ អ្នកដែលលើកពីល្ងាច ចាប់ពីម៉ោងប្រាំពីរដល់ម៉ោងដប់។ ចាប់ពីម៉ោងដប់ដល់ម៉ោងមួយ។ ចាប់ពីម៉ោងមួយដល់ម៉ោងបី។ ចាប់ពីម៉ោងបីដល់ម៉ោងប្រាំទៀបភ្លឺ បាទ។

[១៤:២០:១២]

**ស៖** តើរយៈពេលហ្នឹងវាយូរទេ ច្រើនថ្ងៃទេ ច្រើនសប្តាហ៍ទេ បាទ?

**ឆ៖** បាទ មិនយូរទេ ប្រហែលជាប្រាំថ្ងៃ។

**ស៖** ប្រាំថ្ងៃហ្នឹងធ្វើជាប់គ្នាតែម្តង ឬក៏យ៉ាងម៉េចលោក?

**ឆ៖** បាទ ប្រាំថ្ងៃហ្នឹង គឺធ្វើជាប់ៗគ្នាទាល់តែហើយស្រេច។

**ស៖** លោកចង់មានន័យថា ប្រាំថ្ងៃហ្នឹង គឺធ្វើទាំងយប់ ទាំងថ្ងៃអ៊ីចឹងតែម្តង ឬយ៉ាងម៉េចលោក?

**ឆ៖** បាទ។

**ស៖** ចុះបញ្ហាពាក់ព័ន្ធជាមួយកូនក្រុមរបស់លោកហ្នឹង តើពួកគេអាចស៊ូរួចដោយស្រួល ឬក៏ដោយការលំបាកវេទនាអី លោកអាចប្រាប់បានទេ?

**ឆ៖** បាទ ពេលខ្លះ អ្នកខ្លះស៊ូពុំបាន ដោយងងុយដេកពេក ដេកទាំងរណ្តៅដី។

**ស៖** ចុះចំពោះនារីៗ និងក្មេងជំទង់វិញ យ៉ាងម៉េចដែរ?

**ឆ៖** បាទ ពួកក្មេងជំទង់គេពុំបានឲ្យលើកដូច្នោះទេ។

**ស៖** ចុះចំពោះនារីវិញ?

**ឆ៖** បាទ នារីមានផ្លាស់ប្ដូរដូចគ្នា។

**ស៖** ខ្ញុំមានសំណួរមួយទៀតមុននឹងខ្ញុំបញ្ចប់។ សូមលោកបញ្ជាក់បានទេថា តើនៅពេលដែលលោកធ្វើការហ្នឹង លោកមានសិទ្ធិសេរីភាពក្នុងការចេញទៅផ្ទះ ឬក៏ទៅណា ទៅណី តាមចិត្តរបស់លោកដែរទេ?

**ឆ៖** បាទ អត់បានទេ។

**ស៖** ពេលដែលលោកកំពុងធ្វើការហ្នឹងតើមានឆ្មាំ ឬក៏ទាហានយាមឃ្លាំមើលដែរឬទេ?

**ឆ៖** បាទ នៅពេលយប់មានកងឈ្លបតាមពិនិត្យមើល។

**ស៖** តើពួកគេមានកាំភ្លើងដែរឬទេ?

**ឆ៖** បាទ ខ្លះមាន ខ្លះអត់។

**លោក សេង លាង៖**

សូមអរគុណលោកសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមជូនទៅលោកសហការីអន្តរជាតិ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

សូមអរគុណលោកប្រធាន។ បាទ ជម្រាបសួរលោកចៅក្រម សហការី។

[១៤:២៣:៣៩]

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងលក្ខខ័ណ្ឌការងារសួរបន្តពីសហការីជាតិរបស់ខ្ញុំ។ តើលោកដែលឮនិយាយថា ការដ្ឋានទំនប់ត្រពាំងថ្មហ្នឹងជាសមរភូមិមុខក្ដៅដែរឬទេ?

**លោក កាន ថុល៖**

**ឆ៖** សូមសួរម្ដងទៀត។

**សៈ** បាទ តើលោកដែលឮគេហៅថា "ទំនប់ត្រពាំងថ្ម" ហ្នឹងចាត់ទុកថា ជាសមរភូមិវាយសម្រុកក្ដៅគគុកដែរទេ?

**ឆៈ** ធ្លាប់បានឮ។

**សៈ** តើលោកឮមកពីណាដែរ?

**ឆៈ** ឮគេនិយាយតៗគ្នាថា អាងទឹកត្រពាំងថ្មនេះជាសមរភូមិក្ដៅ។

**សៈ** ហើយពេលដែលលោកឮសូរថាទំនប់ត្រពាំងថ្មជាសមរភូមិក្ដៅហ្នឹង លោកយល់ថាមានន័យយ៉ាងម៉េចដែរ?

**ឆៈ** បាទ ខ្ញុំយល់ថា កន្លែងនោះគឺសមរភូមិដ៏ធំ។

**សៈ** ពីខាងដើមនេះ លោកនិយាយថា ទំនប់ត្រពាំងថ្មបញ្ចប់ទៅនៅឆ្នាំ១៩៧៧។ លោកនៅចាំខែទេ ទំនប់ហ្នឹងគេធ្វើរួចរាល់នៅក្នុងខែណាដែរ?

**ឆៈ** បាទ ទំនប់ហ្នឹងធ្វើរួចរាល់នៅក្នុងខែ៤ មុនចូលឆ្នាំខ្មែរ។

[១៤:២៦:២៣]

**សៈ** ខ្ញុំដឹងថាលោកឆ្លើយពីខាងដើមគឺថា ដំបូងឡើយ គឺចាប់សាងសង់នៅខែកុម្ភៈ ១៩៧៧។ អ៊ីចឹងទំនប់នេះ គឺលើក ឬក៏កសាងនៅចន្លោះពីខែកុម្ភៈ ដល់ខែមេសា ១៩៧៧។ អ៊ីចឹងមែនទេលោក?

**ឆៈ** បាទ។

**សៈ** នៅពេលដែលលោកធ្វើការនៅការដ្ឋាននោះ តើគេមានដែលប្រាប់លោកអំពីពេលវេលាថា ថ្នាក់ដឹកនាំនេះ ចង់ឲ្យទំនប់នេះលើករួចរាល់នៅពេលណាដែរទេ?

**ឆៈ** បាទ ខ្ញុំបានឮគេថា "ធ្វើឲ្យហើយមុនចូលឆ្នាំ"។

**សៈ** លោកដឹងដែរថា អ្នកណាបង្គាប់ថា ទំនប់នេះត្រូវតែធ្វើឲ្យរួចរាល់នៅមុនចូលឆ្នាំខ្មែរ?

**ឆៈ** បាទ គឺឈ្មោះ តាវ៉ាល់។

**សៈ** ហើយចុះ តាវ៉ាល់ ជាអ្នកណាដែរ?

**ឆៈ** តាវ៉ាល់ គឺមេបញ្ជាការដ្ឋានអាងទឹកត្រពាំងថ្ម។

**សៈ** ហើយលោកដឹងទេ ហេតុអ្វីបានជាទំនប់នេះ ត្រូវតែលើក ឬក៏សាងឲ្យរួចរាល់មុនចូលឆ្នាំខ្មែរដូច្នេះ?

**ឆៈ** បាទ អត់ដឹង។

**ស៖** លោកនៅចាំថា លោកធ្លាប់បានឃើញប្រជាជនធ្លាក់ខ្លួនឈឺដែរទេនៅឯការដ្ឋាននុ៎ង?

**ឆ៖** បាទ ឃើញខ្លះ។

**ស៖** តើលោកចាំថាប្រជាជននោះ ធ្លាក់ខ្លួនឈឺដោយសារជំងឺអ្វីខ្លះដែរ? ឬក៏លោកដឹងថាមានរោគសញ្ញាអ្វីខ្លះដែរ?

**ឆ៖** បាទ គឺច្រើនរាករូស ហើយនិងគ្រុនក្ដៅ។

**ស៖** ហើយនៅពេលនោះ លោកមានយល់ ឬក៏ស្វែងយល់ថាហេតុអ្វីក៏ប្រជាជនមានជំងឺរាករូស និងជំងឺគ្រុនក្ដៅអីយ៉ាងដូច្នេះ?

**ឆ៖** មូលហេតុហ្នឹង គឺធ្វើការនៅហាលថ្ងៃ ហាលក្ដៅ ហើយគ្មានអនាម័យ។

**ស៖** ហេតុអ្វីក៏លោកនិយាយថា ចំណីអាហារគ្មានអនាម័យ? តើអាហារដែលគ្មានអនាម័យហ្នឹងវាមានរបៀបលក្ខណៈដូចម្ដេចដែរ?

**ឆ៖** បាទ ពេលនោះវាសម្បូរដោយសត្វរុយច្រើន។

**ស៖** ហេតុអ្វីបានជារុយដ៏ច្រើនបែបនេះធ្វើឲ្យអាហារដូចជាគ្មានអនាម័យ?

**ឆ៖** បាទ ពេលយើងមកទទួលទានអាហារគឺសុទ្ធតែរុយរោមពេញបាយ ពេញសម្លទាំងអស់។

**ស៖** លោកនៅចាំទេថា ប្រជាជនប្រហែលជាប៉ុន្មាននាក់ធ្លាក់ខ្លួនឈឺជារៀងរាល់ថ្ងៃហ្នឹង?

**ឆ៖** បាទ នេះសម្រាប់កងរបស់ខ្ញុំ គឺឈឺក្នុងមួយថ្ងៃ ពីរ បី ទៅ ប្រាំនាក់។

[១៤:៣១:៣៨]

**ស៖** ហើយនៅពេលដែលប្រជាជនធ្លាក់ខ្លួនឈឺគឺមានផ្ដល់ថ្នាំសង្កូវឲ្យពួកគាត់ទេ?

**ឆ៖** បាទ គ្មានទេ។

**ស៖** ដូច្នេះ ប្រសិនណាមាននរណាម្នាក់ធ្លាក់ខ្លួនឈឺ តើអ្នកដែលធ្លាក់ខ្លួនឈឺនោះអាចជាសះស្បើយមកវិញបានដោយរបៀបណាដែរ?

**ឆ៖** បាទ ខ្លះបានជាសះស្បើយវិញដោយរកថ្នាំឱសថបូរាណផឹក។

**ស៖** ហើយចុះអ្នកណាជាផ្ដល់ថ្នាំបូរាណឲ្យហ្នឹង?

**ឆ៖** បាទ នៅប្រចាំកងចល័តនីមួយៗ គឺមានពេទ្យ។

**ស៖** តាមទស្សនៈរបស់លោកនេះ តើលោកយល់ឃើញថាថ្នាំអង្កាល់ហ្នឹង តើថ្នាំហ្នឹងមានប្រសិទ្ធភាព ឬក៏តើមានថ្នាំសម័យអីដែរទេអង្កាល់នុ៎ង?

**ឆ៖** បាទ អត់មានទេ មានតែថ្នាំអាចម៍ទន្សាយ។

**ស៖** តើពេទ្យដែលផ្តល់ថ្នាំ បើកថ្នាំអាចម៍ទន្សាយឲ្យ តើពេទ្យនោះៗលោកមើលទៅថាមានចំណេះផ្នែកខាងពេទ្យដែរទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៤:៣៣:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំជំទាស់ចំពោះសំណួរនេះ។ លើកលែងតែសាក្សីរូបនេះគាត់មានទំនាក់ទំនងជាក់លាក់ណាមួយអំពី -- ជាមួយពេទ្យណាម្នាក់។ បើដូច្នេះសំណួរនេះសួរមិនត្រឹមត្រូវពីព្រោះគាត់មិនមានចំណេះដឹងខាងផ្នែកថ្នាំពេទ្យនោះទេ។ គួរតែសួរសាក្សីថា តើពេទ្យហ្នឹងមានអ្នកណាម្នាក់បានធ្លាប់រៀនមុខវិជ្ជាពេទ្យអីដែរទេ ឬក៏យ៉ាងណាទើបជាការត្រឹមត្រូវ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំអាចសួរអំពីប្រវត្តិពេទ្យទាំងនេះបានបាទ? ខ្ញុំអាចសួរសំណួរពាក់ព័ន្ធទៅនឹងប្រវត្តិរបស់ពេទ្យទាំងនោះបាន។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី លោកដែលឃើញពេទ្យណាម្នាក់ដែលគ្រប់គ្រង ឬក៏ដែលបើកថ្នាំអាចម៍ទន្សាយហ្នឹងទៅឲ្យអ្នកណាម្នាក់ដែលឈឺនោះដែរទេ?

**លោក កាន ថុល៖**

**ឆ៖** បាទ បានឃើញ។

**ស៖** ហើយតើលោកផ្ទាល់នេះ ដែលបាននិយាយទៅកាន់ពេទ្យដែលបើកថ្នាំអាចម៍ទន្សាយមកឲ្យអ្នកជំងឺហ្នឹងដែរទេ?

**ឆ៖** បាទ បាននិយាយ។

**ស៖** ហើយឥឡូវនេះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ពេទ្យទាំងហ្នឹងធ្លាប់បានទទួលការបណ្តុះបណ្តាលផ្នែកជំនាញខាងថ្នាំពេទ្យហ្នឹងពេលណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹង។

**លោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអានចម្លើយមួយផ្នែកដែលគាត់បានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ដើម្បីថាតើគាត់អាចនៅមាន -- ដើម្បីជួយរំឭកដល់ការចងចាំរបស់គាត់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៤:៣៦:១២]

**សួរដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** នេះ គឺជាចម្លើយ E3/7803, ERN ជាភាសាអង់គ្លេស 00277822, ខ្មែរ 00267755 និងបារាំង 00486084។ នេះគឺជាចម្លើយរបស់គាត់ សូមដកស្រង់ “ពេទ្យបានមកព្យាបាល ប៉ុន្តែអត់មានថ្នាំល្អទេ មានតែថ្នាំអាចម៍ទន្សាយទេ។ ពេទ្យទាំងអស់ហ្នឹងមិនមានចំណេះដឹង ឬបទពិសោធន៍អីទេ។ ឧទាហរណ៍ពេទ្យនៅ ផ្ទាល់ នោះដែលគេឲ្យមកព្យាបាលជំងឺនោះ គឺថាមិនអានអក្សរទាំងរួចមួយម៉ាត់ផង។” លោកសាក្សី ដោយឮបែបនេះ តើវាជួយរំឭកដល់ការចង់ចាំរបស់លោកទេ តាមការយល់ឃើញរបស់លោក ពាក់ព័ន្ធទៅនឹងអ្នកដែលបើកចែកចាយថ្នាំនេះ?

**លោក កាន ថុល៖**

**ឆ៖** បាទ វាពិតណាស់។

**ស៖** នៅការដ្ឋាននោះ តើមានទឹកហូបគ្រប់គ្រាន់ដែរទេ?

**ឆ៖** បាទ ដំបូងឡើយ មានទឹកគ្រប់គ្រាន់។

**ស៖** ខ្ញុំយល់ថា វាមានការច្របូកច្របល់បន្តិចនៅក្នុងការបកប្រែ។ សូមសួរឡើងវិញ។ តើនៅការដ្ឋានការងារនោះ លោកអាចមានទឹកបរិភោគទេ?

**ឆ៖** បាទ ដំបូងមានទឹកគ្រប់គ្រាន់ ក្រោយមកពេលដែលចប់ទំនប់អាងហើយទៅលើកទំនប់មួយទៀត គឺពុំមានទឹកគ្រប់គ្រាន់ទេ។

**ស៖** នៅការដ្ឋានទំនប់ត្រពាំងថ្ម លោកដឹងទេ ទឹកដែលលោកហូបនុំង បានមកពីណាដែរ?

**ឆ៖** បាន មកពីបឹង អូរ នៅក្បែរៗនោះ។

**ស៖** លោកដឹងថា ទឹកហ្នឹងត្រូវបានគេបន្សុទ្ធ ឬក៏ធ្វើឲ្យវាមានអនាម័យសិនដែរឬទេ មុនយកទៅឲ្យលោកហូប?

**ឆ៖** បាទ អត់មានទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ពេលនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី អញ្ជើញចូលវិញ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះបន្តនីតិវិធីសវនាការតទៅទៀត។ អង្គជំនុំជម្រះប្រកាសសេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ថ្ងៃសុក្រសប្តាហ៍មុន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងមកថ្លែងរៀបរាប់ពីទុក្ខសោកវេទនា និងព្យសនកម្មដែលពួកគេទទួលរងពាក់ព័ន្ធទៅនឹងការដ្ឋានការងារ ឯកសារ E315/3/3.1។ នាពេលនេះ សហមេធាវីនាំមុខបានស្នើសុំពេលវេលាចំនួនពីរសប្តាហ៍ទៀត ដើម្បីអាចដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលអាចនឹងកែសម្រួល។

សហមេធាវីនាំមុខលើកឡើងថា ពួកគេត្រូវការពេលវេលាបន្ថែមដើម្បីពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរាប់រយពីសំណុំរឿង០៣ និង ០៤ ដែលដាក់បង្ហាញដោយសហព្រះរាជអាជ្ញាទាក់ទិននឹងទំនប់ត្រពាំងថ្ម ហើយដែលរំពឹងថានឹងបានទទួលនៅក្នុងសប្តាហ៍នេះ មុននឹងពិនិត្យមើលថាត្រូវដាក់បញ្ជីកែសម្រួលឬយ៉ាងណា។ ពុំមានភាគីណាមួយជំទាស់ទៅនឹងសំណើសុំនេះទេ។

ទោះបីព័ត៌មានដែលមាននៅក្នុងពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង០០៤ មានការពាក់ព័ន្ធតិចតួចដោយសារមានតែបុគ្គលដែលជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង

០០២ ប៉ុណ្ណោះដែលអាចនឹងត្រូវបានជ្រើសរើសឲ្យមកបង្ហាញខ្លួន ក្នុងអំឡុងពេលស្តាប់សក្ខីកម្មស្តីពីផលប៉ះពាល់នៃអំពើឧក្រិដ្ឋកម្មក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ការកែសម្រួលបញ្ជីឈ្មោះក្នុងរយៈពេលពីរសប្តាហ៍នេះ គឺជាការសមស្របក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ដើម្បីរក្សាសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមការជំនុំជម្រះ។

[១៥:០២:៥២]

ដោយពិចារណាថាការស្តាប់សក្ខីកម្មស្តីពីផលប៉ះពាល់នៃអំពើឧក្រិដ្ឋកម្មនិងសវនាការលើឯកសារគន្លឹះត្រូវបានកំណត់នៅសប្តាហ៍ទី១ ក្នុងខែកញ្ញានោះ បញ្ជីឈ្មោះនេះ នឹងត្រូវកែសម្រួលរួចរាល់មុនពេលសវនាការទាំងនោះ ហើយភាគី និងអង្គជំនុំជម្រះ នឹងទទួលបានការជូនដំណឹងជាមុនគ្រប់គ្រាន់សម្រាប់ត្រៀមលក្ខណៈ។ ហេតុដូចនេះ អង្គជំនុំជម្រះឯកភាពតាមសំណើសុំរបស់សហមេធាវីនាំមុខ ហើយបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកែសម្រួលត្រូវដាក់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥។

សូមលោកព្រះរាជអាជ្ញាបន្តសំណួរដល់សាក្សី!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី នៅមុនពេលឈប់សម្រាកខ្ញុំបានសួរលោកថាតើទឹកដែលលោកហូបនោះពីស្ទឹង ពីអូរហ្នឹង តើត្រូវបានគេបន្សុទ្ធសិនទេមុនឲ្យលោកហូប លោកឆ្លើយថាអត់ទេ។ ហើយខ្ញុំសួរថាលោកដឹងច្បាស់ថា គេមិនបានបន្សុទ្ធទឹកហ្នឹង ឬក៏ធ្វើឲ្យវាមានអនាម័យសិនមុននឹងឲ្យលោកហូប ឬក៏លោកមិនបានដឹងទេ?

**លោក កាន ថុល៖**

**ឆ៖** បាទ ការបន្សុទ្ធ មិនបន្សុទ្ធ ខ្ញុំមិនបានដឹង។

[១៥:០៤:៤១]

**ស៖** តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយដែរទេ នៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម?

**ឆ៖** បាទ បានចូលរួមប្រជុំថ្នាក់តូចៗ។

**ស៖** តើចង់ -- លោកចង់និយាយយ៉ាងម៉េច ដែលថាកិច្ចប្រជុំថ្នាក់តូចៗហ្នឹង អ្នកណាខ្លះចូលរួមនៅក្នុងកិច្ចប្រជុំបែបនេះ?

**ឆ៖** បាទ គឺមានត្រឹមប្រធានវរសេនាតូច។

**ស៖** តើមានន័យថា មានកិច្ចប្រជុំផ្សេងៗទៀតសម្រាប់ថ្នាក់លើ ឬក៏សម្រាប់អ្នកដែលមានឋានន្តរសក្តិខ្ពស់ខ្ពស់ តាមដែលលោកដឹងនោះ?

**ឆ៖** បាទ អត់ដឹង។

**ស៖** ហើយនៅក្នុងអង្គប្រជុំដែលលោកបានចូលរួម តើគេនិយាយអំពីអ្វីដែរ?

**ឆ៖** បាទ អង្គប្រជុំដែលតាមខ្ញុំដឹងហ្នឹង គឺគេពង្រឹងៗសកម្មភាពការលើកទំនប់នេះឲ្យបានខ្លាំងក្លាបំផុត។

**ស៖** អ្នកណាជាអ្នកឡើងនិយាយនៅក្នុងអង្គប្រជុំនោះ?

**ឆ៖** បាទ លោកប្រធានវរៈ។

[១៥:០៧:០២]

**ស៖** ហើយលោកនៅចាំឈ្មោះប្រធានវរៈនេះទេ?

**ឆ៖** បាទ ចាំ។

**ស៖** តើគាត់ឈ្មោះអីដែរ សូមលោកប្រាប់បន្តិចមក?

**ឆ៖** បាទ គាត់ឈ្មោះ រុន។

**ស៖** ហើយការប្រជុំបែបនេះ គេប្រជុំញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ មួយសប្តាហ៍ ទៅ ១០ថ្ងៃម្តង។

**ស៖** ហើយក្នុងតួនាទីរបស់លោកជាមេកងតូចនេះ តើលោកមានផ្តល់ព័ត៌មានដែលលោកបានមកពីកិច្ចប្រជុំហ្នឹង ទៅឲ្យអ្នកណាផ្សេងដែរទេ?

**ឆ៖** បាទ ក្រោយពីមកពីប្រជុំ ហៅកូនក្រុមទាំងអស់ប្រជុំប្រាប់បន្ត។

**ស៖** ហើយការផ្សព្វផ្សាយព័ត៌មានហ្នឹង តើលោកប្រាប់គេអំពីអ្វីដែរ?

**ឆ៖** បាទ គឺប្រាប់អំពីវិន័យ និងអង្គការចាត់តាំង។

**ស៖** តើមេវរៈនោះ នៅពេលដែលគាត់ឡើងនិយាយពេលប្រជុំហ្នឹង តើគាត់មានប្រាប់ថាព័ត៌មានដែលគាត់ឡើងនិយាយពេលប្រជុំហ្នឹង គាត់បានទទួលមកពីអ្នកណាដែរទេ?

**ឆ៖** បាទ គាត់បានមកពីបញ្ជាការដ្ឋាន។

**ស៖** ហើយតាមដែលលោកយល់ហ្នឹង តើពាក្យថា "បញ្ជាការដ្ឋាន"ហ្នឹងមានន័យយ៉ាងម៉េចដែរ?

**ឆ៖** បាទ គឺមេបញ្ជាការនៅការដ្ឋានអាងទឹកត្រពាំងថ្មហ្នឹងឯង។

**ស៖** ហើយមេបញ្ជាការការដ្ឋានអាងទឹកត្រពាំងថ្មហ្នឹងជាអ្នកណា ឈ្មោះអ្វីដែរ?

**ឆ៖** បាទ ឈ្មោះគាត់ឈ្មោះ តាវ៉ាល់។

**ស៖** លោកបាននិយាយថា ប្រធានបទមួយដែលគេលើកយកមកនិយាយនោះ គឺគេនិយាយគ្នាអំពីវិន័យ។ តើពាក្យថា "វិន័យ" នេះ គឺលោកចង់សំដៅថាម៉េច?

**ឆ៖** បាទ វិន័យនេះ គឺឲ្យយើងគោរពពេលវេលា ម៉ោងចេញទៅធ្វើការឲ្យបានទៀងទាត់។

**ស៖** តើនៅក្នុងកិច្ចប្រជុំ គេដែលនិយាយថា នឹងមានអ្វីកើតឡើងទេ បើសិនជាលោកមកធ្វើការមិនទាន់ម៉ោង ឬក៏លោកមិនគោរពវិន័យទេ?

**ឆ៖** បាទ គេមាននិយាយថា បើអ្នកណាមិនគោរពវិន័យ គេនឹងកាត់បន្ថយរបប។

[១៥:១១:៤៦]

**ស៖** លោកដឹងទេថា របបដែលគេកាត់បន្ថយហ្នឹង គេកាត់បន្ថយចំនួនប៉ុនណាដែរ?

**ឆ៖** បាទ ទី១ ៨០ភាគរយ -- សូមទោស ២០ភាគរយ។

**ស៖** លោកនិយាយថា ទី១ ដំបូង លើកទី១ គឺកាត់បន្ថយ២០ភាគរយ បើសិនជាមានករណីមិនគោរពវិន័យ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ចុះបើសិនណាជាមិនគោរពវិន័យជាលើកទី២ លើកទី២នេះគេកាត់បន្ថយប៉ុន្មានដែរ?

**ឆ៖** បាទ ពាក់កណ្តាល។

**ស៖** ចុះបើមានករណីបែបហ្នឹងលើកទី៣ កាត់ប៉ុន្មានទៅ?

**ឆ៖** បាទ ត្រង់នោះខ្ញុំមិនដឹង។

**ស៖** តើការកាត់បន្ថយនេះគេអនុវត្តតែចំពោះការមកធ្វើការមិនទាន់ម៉ោង ឬក៏យ៉ាងម៉េចដែរ ឬក៏ថាគេអាចកាត់បន្ថយរបបអាហារដោយសារមូលហេតុផ្សេងៗទៀតដែរ?

**ឆ៖** បាទ មានខ្លះ បាទកាត់ដោយពេលប្រាប់គេថាឈឺ តែបែរទៅជារោគអ្វីផ្សេង នោះក៏គេកាត់ដែរ។

**ស៖** តើមានទណ្ឌកម្មបែបផ្សេងណាទៀតដែរទេ ដែលនាំឲ្យឈានទៅដល់ការកាត់បន្ថយរបបអាហារនេះ?

**ឆ៖** បាទ ពុំដែលឃើញទេ។

[១៥:១៤:៣៤]

**ស៖** តើលោកមានដឹងថា មានប្រជាជនណា ឬក៏លោកបានជួបប្រទះថាមានប្រជាជនណាដែលត្រូវបានគេកាត់បន្ថយរបបអាហារនេះដែរទេ?

**ឆ៖** បាទ មានឃើញ តែមិនចាំឈ្មោះ។

**ស៖** ហើយប្រជាជនដែលលោកស្គាល់ ដឹងថាគេកាត់បន្ថយរបបអាហារហ្នឹង តើគេចោទប្រកាន់ពួកគាត់ហ្នឹងពីរឿងអ្វីដែរ?

**ឆ៖** គេចោទថាសតិអារម្មណ៍មិនល្អ។

**ស៖** តើមានន័យថាម៉េចលោក ពាក្យថា “មានជំងឺសតិអារម្មណ៍” ហ្នឹង?

**ឆ៖** បាទ និយាយឲ្យចំ គឺអ្នកនោះ បើឈឺក៏ឈឺមិនពិត។

**ស៖** តើលោកធ្លាប់ដែលបានឃើញ បានដឹង បានឃើញ មានប្រតិភូណាមកពិនិត្យមើលការដ្ឋានទំនប់ត្រពាំងថ្មដែរឬទេ?

**ឆ៖** បាទ បានឃើញ។

**ស៖** សូមលោកជម្រាបជូនអង្គជំនុំជម្រះ តើលោកបានឃើញអ្នកណា ប្រតិភូណាដែលមកពិនិត្យមើលការដ្ឋាននោះ?

**ឆ៖** បាទ គឺតាញឹម។

**ស៖** ចុះ តាញឹម នេះជាអ្នកណាលោក?

**ឆ៖** ជាគណៈភូមិភាគពាយ័ព្យ។

**ស៖** លោកបានឃើញគាត់មកពិនិត្យមើលការដ្ឋានហ្នឹងបានប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំឃើញគាត់មកចំនួនបីដង។

**ស៖** នៅពេលដែលគាត់មកពិនិត្យមើលការដ្ឋាននោះ គាត់មកម្នាក់ឯង ឬក៏គាត់មកជាមួយនឹងអ្នកដែលត្រូវមកត្រួតពិនិត្យហ្នឹងផ្សេងទៀតដែរ?

**ឆ៖** បាទ គឺមកមានគ្នាច្រើន ម្តងមានឡានដល់ទៅបីគ្រឿង។

**សៈ** តើលោកនៅចាំទេ អំពីពេលវេលាដែលគាត់មកពិនិត្យមើលការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង លោកឆ្លើយថា លោកបានឃើញគាត់បីដង។ លោកនៅចាំពេលវេលាទេ?

[១៥:១៨:១៧]

**ធៈ** បាទ ពុំបានចាំទេ។

**សៈ** ហើយលោកដឹងទេថា អ្នកណាផ្សេងទៀតដែរ ដែលមកពិនិត្យមើលនៅការដ្ឋានចំនួនបីដង ជាមួយនឹងគាត់ហ្នឹង? អ្នកណាផ្សេងទៀត លោកចាំទេ?

**ធៈ** បាទ អត់ចាំ អត់ស្គាល់។

**សៈ** លោកមានបានឃើញអ្នកណាផ្សេងទៀតមកពីថ្នាក់លើនេះ ចុះពិនិត្យការដ្ឋាននេះដែរទេ ឬក៏ឮសួរគេថា ឮពីអ្នកណាម្នាក់ថា អូ៎! មានថ្នាក់លើមកពិនិត្យការដ្ឋានហ្នឹងដែរ ធ្លាប់ដែលឮ ធ្លាប់ដែលឃើញទេ?

**ធៈ** ខ្ញុំបានឃើញថ្នាក់ដឹកនាំចិនចុះមកម្ដងដែរ។

**សៈ** ខ្ញុំនឹងសួរអំពីចំណុចនេះបន្តិចទៀតនេះ។ ប៉ុន្តែដំបូងនេះ ខ្ញុំសូមអានឲ្យលោកស្ដាប់នូវផ្នែកមួយនៃចម្លើយរបស់លោក។ តើលោកនៅចាំទេ អ្នកដែលមកពិនិត្យមើលការដ្ឋាននោះ គឺERN ជាអង់គ្លេស 00277822 ដល់ 3, បារាំង 00486084, ខ្មែរ 00267756។ សូមដកស្រង់ លោកនិយាយថា៖ "ខ្ញុំបានឃើញថ្នាក់លើចុះមកពិនិត្យមើល អ្នកដែលមានឋានៈខ្ពស់ជាងគេគឺ តាញ៉ឹម ជាមេភូមិភាគនិរតី, តាខ្លែង ជាមេ ហើយ ហ៊ីង្ស ជាប្រធានតំបន់៥ ក៏មកពិនិត្យមើលទំនប់ត្រពាំងថ្ម ដែលមកពិនិត្យមើលជាញឹកញាប់គឺមកស្ទើររាល់សប្ដាហ៍។ ហើយ តាវ៉ាល់ វិញគឺថា គាត់ប្រចាំការនៅទំនប់ត្រពាំងថ្មតែម្ដង ឃើញគាត់ទាំងព្រឹកទាំងល្ងាច"។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេថា លោកបានឃើញ តាខ្លែង និង ហ៊ីង មកពិនិត្យមើលការដ្ឋាននោះដែរ?

**ធៈ** បាទ ពិតមែន។

**សៈ** តើលោកបានឃើញ តាខ្លែង មកមើលការដ្ឋានទ្រុំងប៉ុន្មានដងដែរ?

**ធៈ** បាទ ឃើញម្ដងគត់។

**សៈ** រួចធ្វើម៉េចបានជាលោកដឹងថាគាត់គឺជា តាខ្លែង?

**ធៈ** បាទ ពេលបើកការដ្ឋាន តាញ៉ឹម ហ្នឹងគាត់បានថ្លែងសុន្ទរកថាទៅគាត់ថា នេះគឺឈ្មោះតាខ្លែង គឺរងគាត់។

**សៈ** តើលោកបានឃើញ ហ៊ីង មកពិនិត្យមើលការដ្ឋានហ្នឹងប៉ុន្មានដងដែរ?

**ឆៈ** បាទ គឺឈ្មោះ ហឹង្ស។ ហឹង្ស គាត់មកញឹកញាប់ ជួនកាលមួយសប្តាហ៍ ជួនកាលកន្លះខែគាត់មក។

**សៈ** នៅពេល រស់ ញឹម ទៅពិនិត្យមើលបីដង តើគាត់ធ្វើអ្វីខ្លះក្នុងដំណើរទស្សនកិច្ចរបស់គាត់នោះ ក្នុងការចុះទៅត្រួតពិនិត្យហ្នឹង គាត់ធ្វើអ្វីខ្លះ?

**ឆៈ** បាទ គាត់បានបើកឡាន ហើយក៏ចុះពីលើឡានដើរមើលបងប្អូនកងចល័តហ្នឹងកាប់ដី ហើយគាត់បានសួរថា “តើកាប់ដីហ្នឹងផុយទេ? ហើយរែកដីហ្នឹងបានប៉ុន្មានក្នុងមួយថ្ងៃ?”។

[១៥:២៣:៣២]

**សៈ** នៅពេល ហឹង្ស ទៅពិនិត្យការដ្ឋាន ហើយ តាវ៉ាល់ ទៅពិនិត្យការដ្ឋាន។ ខ្ញុំសុំនិយាយតែពី ហឹង្ស ម្នាក់សិនទៅចុះ។ នៅពេល ហឹង្ស ទៅពិនិត្យមើល តើ ហឹង្ស គាត់ធ្វើអ្វីខ្លះ?

**ឆៈ** បាទ ខ្ញុំឃើញ តាហឹង្ស ទៅពុំដែលបានធ្វើអ្វីទេ គឺគ្រាន់តែគាត់ដើរមើលទៅតាមលើទំនប់តែប៉ុណ្ណោះ។

**សៈ** តើគេមានបានប្រាប់លោកជាមុនថា រស់ ញឹម នឹងមកពិនិត្យមើលការដ្ឋាននោះដែរឬទេ?

**ឆៈ** បាទ គេឲ្យដំណឹងមុន។

**សៈ** តើមានការរៀបចំទុកជាមុនពិសេសណាមួយទេនៅពេលដែល រស់ ញឹម ចុះមកពិនិត្យមើលការដ្ឋាននោះ?

**ឆៈ** បាទ ខ្ញុំមិនដឹង។

**សៈ** តើនៅពេលធ្វើការ -- នៅពេលទំនប់ត្រពាំងថ្មស្ថិតនៅក្រោមការត្រួតត្រារបស់ភូមិភាគនិរតីលោកដឹងថាចាប់ពីណាមកដែរទេ?

**ឆៈ** បាទ ចាប់ពីចុងឆ្នាំ៧៧។

**សៈ** ហើយលោកដឹងថាការដ្ឋាននេះស្ថិតនៅក្រោមការត្រួតត្រារបស់ភូមិភាគនិរតីដោយរបៀបណា?

**ឆៈ** បាទ ខ្ញុំអត់ដឹង។

**សៈ** តើលោកដឹងថា មានការកែប្រែផ្លាស់ប្តូរអ្វីខ្លះដែរទេ នៅពេលដែលខាងនិរតីមកគ្រប់គ្រងការដ្ឋាននោះ?

**ឆ៖** បាទ មានដឹងថានិរតីមក គឺខាងពាយ័ព្យហ្នឹងបាត់មិនឃើញមក។

**ស៖** លោកដឹងទេថាហេតុអ្វីខាងពាយ័ព្យហ្នឹងបាត់ខ្លួន?

**ឆ៖** បាទ អត់ដឹង។

**ស៖** តើស្ថានភាពរស់នៅរបស់លោកកាន់តែយ៉ាប់ៗទៅ ឬក៏វាប្រសើរជាងមុន ឬក៏វានៅដដែល នៅពេលដែលខាងកម្មាភិបាលនិរតីមកគ្រប់គ្រង?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កូប៉េ!

[១៥:២៧:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ថាខ្ញុំមិនមែនជាការជំទាស់ទេ គ្រាន់តែពាក់ព័ន្ធទៅនឹងការរៀបចំតាំងសំណួរតែប៉ុណ្ណោះ។ ខ្ញុំថាខាងភូមិភាគនិរតីនោះគឺមិនបានទៅគ្រប់គ្រងនៅភូមិភាគពាយ័ព្យទេ។ កម្មាភិបាលមួយចំនួនហ្នឹងគឺមានទទួលតួនាទីនៅតាមស្រុក តាមតំបន់មួយចំនួនមែន។ តាមដែលខ្ញុំយល់នោះ គឺថាមិនមានការត្រួតត្រា ឬក៏គ្រប់គ្រងទាំងស្រុងដោយភូមិភាគនិរតីទេ។ គឺគ្រប់គ្រងនៅខែមីនា ១៩៧៧ និងឧសភា ១៩៧៨ ត្រូវ -- គួរណាស់តែសួរថាតើភូមិភាគនិរតីនេះមកគ្រប់គ្រងជាក់លាក់នេះ ពីពេលណា ទៅពេលណា។ បញ្ហានេះគឺពាក់ព័ន្ធទៅនឹងការរៀបចំការតាំងសំណួរតែប៉ុណ្ណោះ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

ខ្ញុំជឿជាក់ថាសាក្សីគាត់បានឆ្លើយហើយ គាត់ដឹងថាកម្មាភិបាលភូមិភាគនិរតីមកចុងខែ -- ១៩៧៧។ កាលណាខ្ញុំនិយាយពីការមកដល់ហ្នឹង គឺខ្ញុំចង់សួរទៅសាក្សីថា តើគាត់ដឹងអំពីការមកដល់របស់កម្មាភិបាលនិរតី ឬក៏អត់?

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាបន្តសំណួរ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

**ស៖** នៅឯការដ្ឋានទំនប់ត្រពាំងថ្ម លោកដែលឃើញគេចាប់ខ្លួនអ្នកណាម្នាក់ដែរទេ?

**លោក កាន ថុល៖**

**ឆ៖** បាទ ពុំដែលឃើញទេ។

[១៥:២៩:១៨]

**ស៖** ខ្ញុំសូមអានចម្លើយមួយ ERN ជាភាសាអង់គ្លេស 00277821, បារាំង 00486083, ខ្មែរ 00267754 ដល់ 55។ សូមដកស្រង់៖ "ថ្ងៃមួយ ខ្ញុំបានឃើញគេចាប់មនុស្សហើយចង ហើយបណ្ដើរគាត់ជិតកន្លែងខ្ញុំស្នាក់នៅក្នុងពេលយប់ ខ្ញុំអត់ស្គាល់ឈ្មោះអ្នកដែលគេចាប់ទេ។ អ្នកដែលមកចាប់គេហ្នឹងគឺថា ស្លៀកពាក់ពណ៌ខ្មៅនិងស្ពាយកាំភ្លើងនៅលើស្មារបស់គេ។ ខ្ញុំគិតថា អ្នកដែលមកចាប់នោះគឺជាកងទ័ព។" បញ្ចប់ការដកស្រង់។ តើវាជួយរំឭកដល់ការចងចាំរបស់លោកថា មានការចាប់ខ្លួនមនុស្សនៅការដ្ឋានទំនប់ត្រពាំងថ្មដែរទេ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីសូមឆ្លើយម្ដងទៀត ពេលឆ្លើយអម្បាញ់មិញហ្នឹងមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក កាន ថុល៖**

**ឆ៖** បាទ នោះជាការពិត។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកដឹងថាអ្នកដែលគេចាប់ខ្លួន អ្នកដែលត្រូវបានគេចាប់ខ្លួនជាអ្នកណាគេ?

**ឆ៖** បាទ អត់ស្គាល់។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន ខ្ញុំដល់ពេលហើយ ហើយអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកព្រះរាជអាជ្ញា។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិការទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរទៅសាក្សី។ សូមអញ្ជើញ!

[១៥:៣១:១៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន មេធាវីនាំមុខសូមអនុញ្ញាតជូនផ្ទេរសិទ្ធិជូនមេធាវី ឡោ ជុនធី ដើម្បីសួរលោកសាក្សីរូបនេះ ជំនួសឲ្យមេធាវីនាំមុខ។ សូមលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ឡោ ជុនធី!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមគោរពអង្គជំនុំជម្រះទាំងមូល និងសូមជម្រាបសួរលោកសាក្សី។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមកពីអង្គការជំនួសផ្នែកច្បាស់នៅកម្ពុជា។ តទៅនេះ ខ្ញុំបាទសូមជម្រាបសួរនូវសំណួរទៅលើលោកពូពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្ម ដែលលោកពូបានទៅធ្វើការនៅទីនោះ។ ហើយអម្បាញ់មិញខាងសហព្រះរាជអាជ្ញាបានលើកសំណួរចំនួនមកហើយ ហើយខ្ញុំសូមសួរសំណួរដែលពាក់ព័ន្ធជាមួយការដ្ឋាននេះ ថាតើនៅក្នុងការដ្ឋាននោះ ដែលលោកពូបានធ្វើការនៅទីនោះៗមានការរៀបការដែរឬទេ? ហើយតើការរៀបការនៅទីនោះ គេរៀបការយ៉ាងដូចម្តេច?

[១៥:៣៣:០៦]

**លោក កាន ថុល៖**

**ឆ៖** បាទ គឺមាន។

**ស៖** បាទ អរគុណ។ មានហ្នឹង ប៉ុន្តែគេការហ្នឹង គេការម្តងប៉ុន្មានគូ ឬមួយគេការម្តងតែមួយគូទេ?

**ឆ៖** បាទ ពេលគេរៀបការម្តងៗមានពី៣០ ទៅ៤០គូ។

**ស៖** តើមុនហ្នឹងការចាប់ឲ្យរៀបការហ្នឹង តើបុរសស្ត្រីអស់នោះ គាត់បានស្គាល់គ្នា ឬមួយដឹងអំពីការរៀបការនោះយ៉ាងដូចម្តេច?

**ឆ៖** បាទ គាត់បានស្គាល់គ្នា ហើយក៏គាត់ពាក់ព័ន្ធគ្នាទៅតាមខ្សែរយៈមេកង មេវរៈរៀងៗខ្លួន។

**ស៖** ខ្ញុំចង់ដឹងថា គាត់ចង់រៀបការ ហើយអីចឹងបានន័យថាគាត់ត្រូវស្នើ ឬមួយគាត់ត្រូវធ្វើយ៉ាងម៉េច?

**ឆ៖** បាទ គឺគាត់ទៅប្រាប់ផ្ទាល់មាត់ដល់ប្រធានកង ផ្នែកយុវជន។ យុវជន ប្រធានកងយុវជនក៏ទៅទាក់ទងប្រធានកងនារី ដើម្បីស្នើសុំ។ ពេលគេយល់ព្រមទើបរៀបការ។

**ស៖** ចុះមានករណីណាដែលៗអ្នកទាំងនោះពុំបានទទួលការ បានន័យថាពុំបានទទួលស្គាល់គ្នា ឬមួយយ៉ាងណានោះ ហើយត្រូវបានគេផ្ដូផ្ដងដោយមិនដឹងខ្លួនទេ?

**ឆ៖** បាទ នៅកងចល័តរបស់ខ្ញុំពុំដែលឃើញទេ។

**ស៖** អរគុណ។ ខ្ញុំសូមបែរទៅខាងការដ្ឋានថាតើអម្បាញ់មិញ លោកបានលើកឡើងអំពីរបបអាហារ ហើយខ្ញុំចង់ដឹងថាតើ សូមឲ្យលោកជម្រាបអំពីរបបអាហារនៅទីនោះ តើគេបែងចែករបបអាហារហ្នឹងយ៉ាងដូចម្ដេចនៅពេលដែលយើងធ្វើការនៅទីនោះ?

**ឆ៖** បាទ ដំបូងគេឲ្យអាហារក្នុងម្នាក់មួយថ្ងៃបីដង។ គឺក្នុងម្នាក់គឺមានរបបអង្ករបីកំប៉ុងក្នុងមួយថ្ងៃ។

**ស៖** ចុះនៅពេលដែលថានៅពេលដំបូងគេឲ្យអ៊ីចឹង ចុះនៅពេលដែលក្រោយមកទៀត តើគេឲ្យដូចម្ដេចដែរ?

**ឆ៖** បាទ ក្រោយមកទៀត គេកាត់បន្ថយមកនៅពីរកំប៉ុង ឬមួយកំប៉ុងកន្លះដោយមិនទៀងទាត់។

[១៥:៣៨:១៧]

**ស៖** ពេលដែលកាត់បន្ថយហ្នឹងមក តើការងារនៅតែដដែល ឬមួយការងារគេបន្ថយដែរ?

**ឆ៖** បាទ ពេលដែលគេកាត់បន្ថយ ក្រោយមកគេឈប់លើកទំនប់ហើយ គេឲ្យចុះជីកប្រឡាយនៅក្រោមទំនប់អាងត្រពាំងថ្ម មកក្រោមទៀត។

**ស៖** នៅពេលដែលរបបអាហារត្រូវបានកាត់បន្ថយហ្នឹង គឺធ្វើឲ្យ បានន័យថាពួកគាត់ត្រូវបានចុះខ្សោយនូវកម្លាំង ដូច្នេះ គាត់នឹងមាន -- តើអ្នកទាំងនោះហ្នឹង គាត់ឈឺ ឬមួយអត់ឈឺទេ ឬមួយគាត់នៅមានកម្លាំងលើកដី បានដដែល ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ ពេលនោះកម្លាំងក៏ចេះខ្សោះ ចុះខ្សោយតាមនោះទៅ។

**ស៖** លោកអម្បាញ់មិញបានលើកឡើងថា គេកាត់បន្ថយ ហើយចុះទៅជីកប្រឡាយ។ ខ្ញុំអត់យល់ថា តើចុះជីកប្រឡាយនុ៎ង ជីកប្រឡាយនៅខាងណា ឬមួយនៅទំនប់ហ្នឹងដដែល ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ គេចាប់ជីកប្រឡាយបន្តពីក្រោមអាងទឹកត្រពាំងថ្មនោះ ទៅក្រោម។

**ស៖** ចុះលោកថាបានធ្វើការងារនៅទំនប់ត្រពាំងថ្មហ្នឹងរហូតដល់ចប់។ តើនៅក្នុងរយៈពេលហ្នឹង លោកមានបានត្រូវគេចាត់តាំងឲ្យទៅធ្វើទំនប់ណាផ្សេងទេ?

**ឆ៖** បាទ គឺមានទៅធ្វើទំនប់មួយទៀត នៅតំបន់កូនខ្ពែង។

**សៈ** តំបន់កូនខ្លែងហ្នឹងនៅជិតហ្នឹង ឬមួយឆ្ងាយពីហ្នឹង? ហើយការដែលទៅធ្វើហ្នឹង ទៅទាំងអស់គ្នា ឬមួយទៅតែប៉ុន្មាននាក់?

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីការពារលោក ខៀវ សំផន។ សូមអញ្ជើញ!

[១៥:៤២:០៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា លោកមេធាវីប្រហែលជាច្រឡំទៅលើអង្គហេតុដែលសាក្សីបញ្ជាក់ប្រាប់។ លោកសួរអំពីអំឡុងពេលនៃការដែលសាក្សីធ្វើការនៅលើទំនប់ត្រពាំងថ្ម ប៉ុន្តែសាក្សីបានឆ្លើយ គឺឆ្លើយពេលក្រោយ ឬក៏បញ្ចប់ការងារទំនប់ត្រពាំងថ្ម។ ដូច្នេះសំណួរ និងចម្លើយនេះ អត់ចូលគ្នាទេ ហើយសាក្សីដែលលោកបញ្ជាក់អំពីការធ្វើការនៅតំបន់កូនខ្លែងនោះ គឺក្រោយពេលការលើកទំនប់។ បាទ សូមអរគុណ។

**លោក ឡៅ ជុនធី៖**

បាទ ខ្ញុំនឹងកែសម្រួលសំណួរឡើងវិញ។

**សួរដោយលោក ឡៅ ជុនធី៖**

**សៈ** អ៊ីចេះ ខ្ញុំសូមលើកទៅបរិបទមួយទៀត ថាតើនៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម លោកបានលើកឡើងហើយថាមានការប្រជុំ។ តើមានការប្រជុំណាផ្សេងពីការប្រជុំដែលបាន -- លោកបានលើកឡើងទេ ដូចជាប្រជុំហៅថា "ទិតៀន ស្វ័យទិតៀន" តើមានទេ?

[១៥:៤៣:៤២]

**លោក កាន ថុល៖**

**ឆៈ** បាទ ប្រជុំទិតៀន និងស្វ័យទិតៀនហ្នឹង គឺជីវភាព សឹងតែរាល់តែថ្ងៃ។

**សៈ** ចំណុចមួយទៀត នៅពេលដែលយើងទទួលអនុវត្តនូវផែនការ បានន័យថាប្រជុំគេមានផែនការ ទទួលអនុវត្តផែនការ ហើយប្រសិន -- មិនមែនប្រសិនបើទេ គឺថានៅពេលអនុវត្តផែនការហើយ ដល់ពេលដូចយើងអនុវត្តមិនបាននោះ តើមានការដាក់ទណ្ឌកម្មហ្នឹង គឺដាក់ទណ្ឌកម្មបែបដូចម្ដេចខ្លះ?

**ឆៈ** បាទ ហ្នឹងគឺខ្ញុំបានបញ្ជាក់ហើយ គឺទណ្ឌកម្មដែលដាក់ហ្នឹង គឺគ្មានអ្វីក្រៅពីកាត់របបទេ។

**ស៖** កាត់របបបានន័យថា កាត់របបរហូតទៅដល់អ្នកហ្នឹងកែប្រែវិញ ឬមួយកាត់របបយូរៗទៅ អ្នកហ្នឹងមិនអាចធ្វើការកើត គេនៅតែកាត់របបបន្តទៀត ឬមួយម៉េច?

**ឆ៖** បាទ បើអ្នកឈឺពិត គេពុំបានកាត់របបទេ តែបើអ្នកឈឺសតិអារម្មណ៍ដែលគេមើលឃើញគេកាត់ ក្រោយមកអ្នកនោះដឹងខ្លួន ត្រឡប់ទៅធ្វើការធម្មតាវិញ។

**ស៖** តើនៅទីនោះ លោកថាមានកុមារវ័យជំទង់ តើកុមារវ័យជំទង់ហ្នឹងគាត់លើកតាមផែនការ ៣ម៉ែត្រគូបហ្នឹងដែរ ឬមួយខុសពីហ្នឹង?

**ឆ៖** បាទ គាត់អត់បានលើកវាស់វែងទេ គឺគាត់លើកជាសមូហភាព។

[១៥:៤៦:៤៤]

**ស៖** នៅពេលដែលលោកថា នៅក្នុងកងមាន៣០នាក់។ ពេលដែលទទួលបញ្ជាមកយើងបានប្រជុំនៅក្នុងកង។ តើនៅក្នុងកងហ្នឹងគេធ្វើការជាលក្ខណៈឯកជនម្នាក់ៗ ឬមួយគេធ្វើរួមដែរ? បានន័យថា៣០នាក់ គេឲ្យម្នាក់៣ម៉ែត្រគូប ចុះបើ៣ម៉ែត្រគូបលើកអត់រួច មានអ្នកអាច អ្នកក្រៅអាចជួយបានដែរអត់ទេ?

**ឆ៖** បាទ បើអ្នកណាលើកមិនរួច មានមេកង ឬអនុកង សមាជិកកងម្នាក់អាចជួយបាន។

**ស៖** អរគុណ។ តើមេកង ឬអនុកងហ្នឹងគាត់ទទួលដូចគ្នា ដូចកងដែរ ឬមួយយ៉ាងដូចម្ដេច?

**ឆ៖** បាទ មេកងបីនាក់នោះពុំបានវាស់ដូចអ្នកដទៃទេ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសល់ពេលបន្តិចបន្តួច សូមផ្ទេរទៅសហមេធាវីនាំមុខបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមអរគុណសហភាតាដែលបានផ្ដល់ពេលវេលាឲ្យខ្ញុំបន្តិចបន្តួច ពីព្រោះថាខ្ញុំចង់សួរសំណួរមួយចំនួនតូចទេ ពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្វីដែលលោកបានឆ្លើយពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍។

លោកបាននិយាយអំពីគេរៀបការម្ដង៣០ទៅ៤០គូ ខ្ញុំចង់ដឹងថាតើការរៀបការហ្នឹងគឺធ្វើឡើងនៅការដ្ឋានតែម្ដង ឬក៏នៅកន្លែងផ្សេង?

[១៥:៤៩:៣៦]

**លោក កាន ផុល៖**

**ឆ៖** បាទ ធ្វើនៅនឹងការដ្ឋានកងចល័តហ្នឹង។

**ស៖** ចុះលោកផ្ទាល់ តើលោកមានតួនាទីអ្វីនៅក្នុងពេលគេរៀបអាពាហ៍ពិពាហ៍នុំង?

**ឆ៖** បាទ ខ្ញុំមានតួនាទីជាភ្ញៀវកិត្តិយស បានទៅចូលរួម។

**ស៖** នៅសម័យនោះ តើលោកមានទទួលបានការពន្យល់បំភ្លឺទេ ថាហេតុអ្វីបានជាគេរៀបការម្ដងច្រើនៗគូបែបនេះនៅនឹងការដ្ឋាន?

**ឆ៖** បាទ គេបានពន្យល់ប្រាប់ខ្លះៗដែរ។ គេថា ពីដើមមិញ ឪពុកម្ដាយរៀបការសុទ្ធតែអស់លុយអស់កាក់ ធ្វើតុ ធ្វើទូ អស់ច្រើនណាស់។ ឥឡូវសម័យនេះ មិនបាច់អស់អ្វីទេ គ្រាន់តែយើងគោងដៃគ្នា ចាប់ដៃគ្នារួច ជាការស្រេច។

**ស៖** ក្រោយពីរៀបការហើយភ្លាម តើប្ដីប្រពន្ធហ្នឹងរស់នៅជាមួយគ្នាទេ?

**ឆ៖** បាទ ប្ដីប្រពន្ធហ្នឹងមានមេប្រធានវរៈហ្នឹង គាត់ឲ្យរស់នៅជាមួយគ្នាបានចំនួនបីថ្ងៃ។

**ស៖** ហើយក្រោយពីបីថ្ងៃហ្នឹងមក មានរឿងអីកើតឡើងទៀតចំពោះពួកគេ។

**ឆ៖** បាទ ក្រោយពីបីថ្ងៃ ១០ថ្ងៃគេឲ្យជួបគ្នាម្ដង។

**ស៖** តើលោកដឹងទេថា ឪពុកម្ដាយរបស់ប្ដីប្រពន្ធហ្នឹងបានទទួលដំណឹងថា កូនៗរបស់ពួកគាត់រៀបការទេ ហើយនៅពេលរៀបការហ្នឹង ពួកគាត់មានវត្តមាននៅពេលនោះទេ?

**ឆ៖** បាទ ពុំដែលមានទេ។

[១៥:៥៣:០០]

**ស៖** ដើម្បីឲ្យបានច្បាស់គឺ មានន័យថា ពួកគាត់មិនបានដឹងថា កូនរបស់ខ្លួនរៀបការទេ ហើយក៏មិនមានវត្តមាននៅពេលរៀបការហ្នឹងដែរ លោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** លោកបានឆ្លើយថា គេអញ្ជើញលោកឲ្យធ្វើជាភ្ញៀវកិត្តិយសក្នុងពេលរៀបការ។ តើលោកអាចប្រាប់បានទេថា នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មនោះ លោកបានចូលរួមក្នុង

ពិធីរៀបការហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** បាទ គឺបានចូលរួមម្ដង។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថា ប្ដីប្រពន្ធរស់នៅជាមួយគ្នាបីថ្ងៃ បន្ទាប់មកត្រឡប់ទៅធ្វើការងារវិញ។ អ៊ីចឹងនៅក្នុងរយៈពេលបីថ្ងៃដែលនៅជាមួយហ្នឹង ពួកគាត់រស់នៅកន្លែងណា?

**ឆ៖** បាទ គឺមានមេវរៈទាក់ទងគ្នាជាមួយនឹងសហករណ៍ណាដែលនៅជិត ហើយក៏សុំផ្ទះតាមផ្ទះអ្នកស្រុកហ្នឹង គឺឲ្យស្នាក់នៅ។

**ស៖** លោកបានបញ្ជាក់ថា ១០ថ្ងៃម្ដង ពួកគាត់អាចជួបគ្នាវិញ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើ នៅពេលដែលប្ដីឬក៏ប្រពន្ធចង់ទៅជួបគ្នាអ៊ីចឹងមានសុំការអនុញ្ញាតពីថ្នាក់លើទេ ឬក៏មានប្រព័ន្ធរៀបចំយ៉ាងម៉េចផ្សេងវិញ?

[១៥:៥៥:00]

**ឆ៖** បាទ ពេលនោះ គេមានការចាត់តាំងច្បាស់លាស់ថា គឺអ្នកដែលបានប្ដីប្រពន្ធហើយ គឺរាប់ចាប់ពីបីថ្ងៃទៅដល់១០ថ្ងៃ គឺត្រូវមកជួបជុំប្រពន្ធកូនដោយខ្លួនឯង។

**ស៖** អ៊ីចឹង គាត់ត្រូវសុំការអនុញ្ញាតទេដើម្បីធ្វើដំណើរទៅជួបគ្នាហ្នឹង? ឬក៏មិនបាច់ចាំសុំអនុញ្ញាតទេ គឺទៅជួបតែម្ដង?

**ឆ៖** បាទ ខ្លះនៅជិតពុំបាច់សុំទេ តែបើអ្នកនៅឆ្ងាយ ហ្នឹងគឺសុំលិខិតឧទ្ទេសនាម។

**ស៖** អ្នកណាជាអ្នកចេញលិខិតឧទ្ទេសនាមហ្នឹង? លោកដឹងទេថាពេលដែលប្ដីប្រពន្ធចង់ទៅជួបគ្នាហ្នឹងគាត់សុំលិខិតឧទ្ទេសនាមហ្នឹងពីអ្នកណាដែរ?

**ឆ៖** បាទ គឺត្រឹមថ្នាក់វរៈ បាទ ប្រធានវរៈ។

**ស៖** សំណួរចុងក្រោយពីព្រោះដល់ម៉ោងបួនហើយ។ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យតើលោកមានបានរៀបការទេ?

**ឆ៖** បាទ ពុំបានទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

លោកប្រធានសូមអរគុណ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីមេធាវី។

ឥឡូវនេះ ដល់ពេលវេលាសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ទី១១ ខែសីហា ឆ្នាំ២០១៥ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី កាន ថុល ហើយនិងផ្តើមសក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-889 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី 2-TCW-889 អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-937។ អង្គជំនុំជម្រះអរគុណចំពោះលោក កាន ថុល ដំណើរការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក កាន ថុល វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក ទី១១ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោង ប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោកជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃអង្គារ ទី១១ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*